# របាយការណ៍ប្រចាំឆ្នាំ២០២០

## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ទស្សនវិស័យ

ធ្វើឱ្យជីវភាពប្រជាជននៅជនបទប្រសើរឡើង ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាពតាមរយៈគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមាននិរន្តរភាពហិរញ្ញវត្ថុ។

## បេសកកម្ម

ផ្តល់សេវាកម្មហិរញ្ញវត្ថុដល់សហគមន៍និងសហគ្រាសខ្នាតតូចនៅជនបទប្រកបដោយនិរន្តរភាព។

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|
| ទ្រព្យសកម្មសរុប | ១៨.៦២៨.០៤១ | ១២.៦២៦.៥១៤ |
| បំណុលសរុប | ១២.៥២៩.៣៤១ | ១០.៩៥៥.៧២៧ |
| មូលធនសរុប | ២.០៩៨.៧០០ | ១.៦៧០.៧៨៧ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ឆ្នាំ២០២០** | **ឆ្នាំ២០១៩** |
| ចំណូលសរុប | ១.៨២៥.៥៩៨ | ១.៥៦៤.៨៦៥ |
| ចំណេញ/(ខាត)មុនបង់ពន្ធ | ៥៥១.៥៧៥ | ៥២៤.៥២១ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ៤៤៣.៥១៨ | ៤១៩.៤០៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៤២៧.៧៣៥ | ៤៣៩.២៣២ |
| **អនុបាតហិរញ្ញវត្ថុ (សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ)** | **ឆ្នាំ២០២០** | **ឆ្នាំ២០១៩** |
| អនុបាតសាធនភាព | ១៨,៩១% | ២០,២៣% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥៩៧,០០% | ៦៥៥,៧២% |
| អនុបាតសន្ទនីយភាព | ២៣២,៧៨% | ១៧២,៩៤% |
| អនុបាតឥណទានមិនដំណើរការ | ១,៣៧% | ០,៣១% |
| អនុបាតប្រាក់បញ្ញើធៀបនឹងឥណទាន | ៦៩,២១% | ៧២,៤៦% |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មជាមធ្យម [1] | ៣,២៥% | ៣,៧៩% |
| អនុបាតចំណេញធៀបនឹងមូលធនជាមធ្យម [1] | ២៣,៥៣% | ២៨,៩០% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ១៦៨,១៨% | ១៧៨,៦៦% |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនបើមាន) | គ្មាន | គ្មាន |

[1] អនុបាតត្រូវបានគណនាលើប្រាក់ចំណេញសុទ្ធរយៈពេល១២ខែគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

## ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប


















## ស្ថិតិសង្ខេបប្រចាំឆ្នាំអំពីលទ្ធផលប្រតិបត្តិការ

| ស្ថិតិអំពីលទ្ធផលប្រតិបិត្តការ (គិតជាលានរៀល) | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---:|---:|
| ទ្រព្យសកម្មសរុប | ១៤.៦២៨.០៤១ | ១២.៦២៦.៥១៤ |
| មូលធនសរុប | ២.០៩៨.៧០០ | ១.६៧០.៧៨៧ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ៤២៧.៧៣៥ | ៤៣៩.២៣២ |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មជាមធ្យម (១) | ៣,២៥% | ៣,៧៩% |
| អនុបាតចំណេញធៀបនឹងមូលធនជាមធ្យម (១) | ២៣,៥៣% | ២៨,៩០% |
| សម្លៀតឥណទានសរុប | ១២.០៤៨.៣៥៦ | ១០.០៥៨.០១៩ |
| សមតុល្យប្រាក់បញ្ញើសន្សំសរុប | ៨.៣៣៨.២១៩ | ៧.២៨៨.២៧២ |
| អនុបាតប្រាក់បញ្ញើធៀបនឹងឥណទាន | ៦៩,២១% | ៧២,៤៦% |
| អនុបាតសាធនភាព | ១៨,៩១% | ២០,២៣% |
| អនុបាតសន្ទនីយភាព | ២៣២,៧៨% | ១៧២,៩៤% |
| អនុបាតហានិភ័យផលប័ត្រឥណទាន >= ៣០ថ្ងៃ | ១,៨៨% | ០,៣៦% |
| អនុបាតផលប័ត្រឥណទានធៀបនឹងទ្រព្យសកម្ម | ៨២,៣៦% | ៧៩,៦៦% |
| ចំណាយប្រតិបត្តិការធៀបនឹងផលប័ត្រឥណទានជាមធ្យម | ៣,៣១% | ៣,៥៨% |
| អនុបាតចំណាយធៀបនឹងចំណូល | ៣៦,០៦% | ៣៥,៥៣% |
| អត្រាចំណូលលើផលប័ត្រឥណទានជាមធ្យម | ១៦,០៤% | ១៦,៥០% |

# ក្រុមប្រឹក្សាភិបាល



លោក Kwi Sang JUN
ប្រធានក្រុមប្រឹក្សាភិបាល



លោក Hwan Kook KIM
អភិបាលឯករាជ្យ



លោក Hana LEE
អភិបាលឯករាជ្យ



លោក បែល សក្តិភក្តី
អភិបាលឯករាជ្យ



លោក Ishara C. Nanayakkara
អភិបាល



លោក Minki Brian HONG
អភិបាល



លោក ស៊ីម សេនាជាតិ
អភិបាល



លោក Hak Soo KIM
អភិបាល



លោក Ji Kyu JANG
អភិបាល

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

យើងខ្ញុំមានសេចក្តីសោមនស្សសូមបង្ហាញជូន លោក លោកស្រី នូវលទ្ធផលហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ប្រចាំឆ្នាំ២០២០ ស្របតាមតម្រូវការរបស់និយ័តករមូលបត្រកម្ពុជា (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា)។

ជាផ្នែកមួយនៃការឆ្លើយតបជាសកលចំពោះការរីករាលដាលនៃជំងឺរាតត្បាត កូវីដ-១៩ យើងខ្ញុំកំពុងតែជួបប្រទះនឹងបញ្ហាប្រឈមចម្បងៗ ព្រមទាំងបទពិសោធន៍ស្តីពីការបង្ខាំងសេដ្ឋកិច្ចពិភពលោក ការបង្ខាំងមិនឱ្យចេញចូលតាមប្រទេសនានា ការកាត់បន្ថយការធ្វើដំណើរ ការបន្តអនុវត្តគម្លាតសង្គម និងការពាក់ម៉ាស់ជាប្រចាំ ដើម្បីការពារការចម្លងជំងឺនៅជុំវិញពិភពលោក។ ប្រទេសទាំងអស់ បានចាប់ផ្តើមបើកដំណើរការសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ការអនុញ្ញាតឱ្យធ្វើដំណើរខ្លះៗ ដោយកត់សម្គាល់ថា យើងខ្ញុំប្រហែលជាជួបប្រទះនឹងរលកទីពីរ ឬទីបី នៃជំងឺនេះ ដោយសារតែវ៉ាក់សាំង បាននឹងកំពុងតែផលិត និងចែកចាយ។ ប្រទេសមួយចំនួនបានកំពុង ធ្វើការចាក់វ៉ាក់សាំង និងប្រទេសមួយចំនួនទៀត កំពុងរង់ចាំការមកដល់នូវវ៉ាក់សាំង ដោយថិរវេលានៃការរង់ចាំ និងការចាក់វ៉ាក់សាំងជូនដល់ ប្រជាជនទាំងអស់ជុំវិញពិភពលោក នឹងចំណាយពេលយ៉ាងហោចណាស់ពី ៦ ដល់ ១២ខែ។

ក្នុងរយៈពេលពីរទសវត្សកន្លងមក ប្រទេសកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរដ៏សំខាន់មួយ ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥ និងមានបំណងក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០។ ដោយមានការជំរុញ ពីការនាំចេញសម្លៀកបំពាក់ និងវិស័យទេសចរណ៍ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា មានអត្រាកំណើនជាមធ្យម ៨% ក្នុងចន្លោះឆ្នាំ ១៩៩៨ និង ២០១៨ ដែលធ្វើឱ្យប្រទេសកម្ពុជាបានក្លាយជាប្រទេសមួយ ដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតនៅលើពិភពលោក។ ខណៈពេលដែលមានការធ្លាក់ចុះបន្តិចបន្តួចក្តី ប៉ុន្តែកំណើននៅតែមានភាពរឹងមាំដែលត្រូវបានប៉ាន់ប្រមាណថាអាចនឹងឈានដល់ ៧,១% ក្នុងឆ្នាំ ២០១៩ បើប្រៀបធៀបទៅនិងអត្រាកំណើនដែលល្អប្រសើរជាងការរំពឹងទុក ៧,៥% ក្នុងឆ្នាំ ២០១៨។

ការភ្ញាក់ផ្អើលនៃសាកលលោក ដែលបង្កឡើងដោយការរីករាលដាលនៃជំងឺរាតត្បាត កូវីដ-១៩ បានប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០២០ នៅពេលដែលប្រទេសកម្ពុជាក៏ប្រឈមនឹងការផ្អាកផ្នែកខ្លះនៃការចូលទៅកាន់ទីផ្សារអឺរ៉ុបក្រោមប្រព័ន្ធអនុគ្រោះពន្ធ "អ្វីៗទាំងអស់លើកលែងតែអាវុធ"។ ការផ្ទុះឡើងជំងឺកូវីដនេះបណ្តាលឱ្យមានការថយចុះយ៉ាងខ្លាំងទៅលើវិស័យសំខាន់ៗរបស់ប្រទេសកម្ពុជា ដូចជាវិស័យទេសចរណ៍ ផលិតកម្មសម្រាប់ការនាំចេញ និងសំណង់ ដែលបានចូលរួមចំណែកច្រើនជាង ៧០ ភាគរយនៃកំណើនរបស់ប្រទេស និងជិត ៤០ ភាគរយនៃចំណាយការងារ។ សេដ្ឋកិច្ចនៅឆ្នាំ ២០២០ ត្រូវបានគេរំពឹងថានឹងមានអត្រាកំណើនអវិជ្ជមាន -២% ដែលជាការធ្លាក់ចុះខ្លាំងបំផុតក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា។ ការរីករាលដាលនៃជំងឺរាតត្បាត កូវីដ-១៩ និងការងើបឡើងវិញយឺតនៃសេដ្ឋកិច្ចពិភពលោក ទន្ទឹមនឹងភាពរឹតរឹននៃទីផ្សារហិរញ្ញវត្ថុ ដែលបានអូសបន្លាយអស់រយៈពេលយ៉ាងយូរ ដែលបង្កហានិភ័យជាច្រើនដល់ទស្សនវិស័យកំណើនរបស់កម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា បានខិតខំយ៉ាងខ្លាំងក្នុងការជួយដល់វិស័យសង្គមកិច្ច សេដ្ឋកិច្ច និងជាពិសេសផ្នែកហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកថាជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ។ ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំនៅខែមីនា និងខែវិច្ឆិកា ឆ្នាំ២០២០ និងបន្តការណែនាំក្នុងការផ្តល់រយៈពេលអនុគ្រោះ និងការរៀបចំសងប្រាក់កម្ចីឡើងវិញដល់អាជីវកម្មដែលរងផលប៉ះពាល់ដោយជំងឺ កូវីដ-១៩។

ជាលទ្ធផលនៅចុងឆ្នាំ ២០២០ ទ្រព្យសកម្មសរុបនៃវិស័យហិរញ្ញវត្ថុមានចំនួន ៣.៦១៦ លានដុល្លារអាមេរិក កើនឡើងប្រមាណ ១៦,៧១% បើប្រៀបធៀបនិងឆ្នាំ ២០១៩ សម្លៀតឥណទានសរុបមានចំនួន ២.៩៧៩ លានដុល្លារអាមេរិក កើនឡើង

ប្រហែល ២០,៦៨% បើប្រៀបធៀបនឹងឆ្នាំ ២០១៩ ខណៈដែលសមតុល្យប្រាក់បញ្ញើសរុបមានចំនួន ២.០៦១ លានដុល្លារអាមេរិក កើនឡើង ប្រហែល ១៥,២៥% ប្រៀបធៀបនិងឆ្នាំ ២០១៩។

ទោះបីជាមានភាពមិនប្រាកដប្រជានៅពេលនេះក៏ដោយ ប្រាសាក់នៅតែបន្តរីកចម្រើនលើគ្រប់ផ្នែក រួមបញ្ចូលទាំង ទ្រព្យសកម្ម សមតុល្យប្រាក់បញ្ញើ និងសម្ពៀតឥណទាន ប្រាក់ចំណេញ ក៏ដូចជាបច្ចេកវិទ្យាហិរញ្ញវត្ថុ។ យើងខ្ញុំបានគ្រប់គ្រង ក្នុងការផ្ទេរភាពជាម្ចាស់ដោយរលូន និងបានចុះបញ្ជីមូលបត្របំណុលសាជីវកម្មប្រាសាក់ដោយជោគជ័យនៅផ្សារមូលបត្រកម្ពុជា។ ការបោះផ្សាយមូលបត្របំណុលជាលើកដំបូងរបស់ប្រាសាក់ បង្ហាញពីការប្រមូលមូលនិធិដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្រផ្សារភាគហ៊ុន របស់កម្ពុជា។ ប្រាសាក់ អាចធ្វើការប្រមូលមូលនិធិបន្ថែមចំនួន ១២៧.២ ពាន់លានរៀល (៣១.១៨ លានដុល្លារអាមេរិក) តាមរយៈ ការបោះផ្សាយមូលបត្របំណុលសាជីវកម្ម សម្រាប់ការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅផ្សារមូលបត្រកម្ពុជា។

ថ្វីត្បិតតែយើងខ្ញុំកំពុងតែជួបប្រទះ នឹងបញ្ហាប្រឈមចម្រុងៗ ព្រមទាំងបទពិសោធន៍ស្តីពីវិបត្តិសេដ្ឋកិច្ចពិភពលោក យើងខ្ញុំ នៅតែផ្តល់ប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដ៏រឹងមាំ និងស្របជាមួយអត្ថប្រយោជន៍រយៈពេលវែងរបស់ម្ចាស់ភាគហ៊ុន។ យើងខ្ញុំ បានរៀនសូត្រពីបញ្ហាប្រឈមជាច្រើនឆ្នាំកន្លងមក ដែលធ្វើឱ្យប្រាសាក់ក្លាយជាស្ថាប័នរឹងមាំ និងមានស្ថិរភាពក្នុងរយៈពេលជាង ២៥ ឆ្នាំនៃកំណើនប្រកបដោយចីរភាព។ ជាលទ្ធផលនៅចុងត្រីមាសទី៤ ឆ្នាំ ២០២០ ទ្រព្យសកម្មសរុបមានចំនួន ៣.៦១៦ លានដុល្លារ អាមេរិក កើនឡើង ១៦,៧១% បើប្រៀបធៀបនឹងត្រីមាសដូចគ្នានៃឆ្នាំ២០១៩។ សមតុល្យប្រាក់បញ្ញើ បានកើនឡើងដល់ ២.០៦១ លានដុល្លារអាមេរិក ហើយសម្ពៀតឥណទានសរុបមានចំនួន ២.៩៧៩ លានដុល្លារអាមេរិក។ មូលធនសរុបបានកើនឡើងនិង ឈានដល់ ៥១៩លានដុល្លារអាមេរិក ក្នុងរយៈពេលនៃរបាយការណ៍នេះផងដែរ។

ទោះបីឆ្នាំ២០២០ គឺជាឆ្នាំដែលមានបញ្ហាប្រឈមខ្លាំងមិនធ្លាប់មានក៏ដោយ ក្រុមប្រឹក្សាភិបាល និងភាគទុនិកមានទំនុក ចិត្តថា ភាពជាអ្នកដឹកនាំ យុទ្ធសាស្ត្រ និងបុគ្គលិករបស់ប្រាសាក់ នឹងជួយឱ្យប្រាសាក់បន្តទទួលបានជោគជ័យខ្ពស់សម្រាប់គ្រប់ភាគី ពាក់ព័ន្ធទាំងអស់។ ក្នុងរយៈពេលពីរឆ្នាំខាងមុខ ប្រាសាក់ពុំទាន់មានគំរោងដើម្បីប្រមូលមូលនិធិបន្ថែម ឬ បោះផ្សាយលក់មូលបត្រ ជាសាធារណៈលើកដំបូងពីទីផ្សារមូលបត្រកម្ពុជានៅឡើយទេ។

ក្នុងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ប្រាសាក់ ចំពោះការខិតខំប្រឹងប្រែង ដោយភាពស្វាហាប់ និងការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធ្វើឱ្យអាជីវកម្មរីកលូតលាស់ ស្របនឹងកំណើនអតិថិជនប្រកបដោយ ភាពសុខដុម។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាភិបាល ភាគទុនិក អតិថិជន រាជរដ្ឋាភិបាលកម្ពុជា និងជាពិសេស ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជា (ពីមុនជាគណៈកម្មការមូលបត្រកម្ពុជា) និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដែល បានគាំទ្រ និងផ្តល់ដំបូន្មានជាប្រចាំ។

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
ហៅកាត់ថា ប្រាសាក់មីក្រូហិរញ្ញវត្ថុ ម.ក
PRASAC MICROFINANCE INSTITUTION PLC.
"PRASAC MFI PLC."
សាខាការិយាល័យកណ្តាល

**Kwi Sang JUN**

ប្រធានក្រុមប្រឹក្សាភិបាល

## សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

ជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងឆាប់រហ័សដល់ជីវិតរបស់យើងទាំងអស់ រាប់ចាប់ពីរបៀបដែលយើងធ្វើការ និងធ្វើដំណើរ រហូតដល់របៀបដែលយើងប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជារៀងរាល់ថ្ងៃ។ ជាមួយនឹងវិបត្តិសេដ្ឋកិច្ចជាសកល ឥឡូវនេះយើងកំពុងរស់នៅក្នុងភាពមិនច្បាស់លាស់ និងប្រែប្រួលខ្លាំង។

ដូចក្រុមហ៊ុនជាច្រើនដែរ យើងខ្ញុំបានផ្អាកការធ្វើដំណើររបស់បុគ្គលិក និងផ្អាកនូវព្រឹត្តិការណ៍ និងការប្រជុំធំៗនានា។ នៅការិយាល័យកណ្តាលយើងខ្ញុំ បានផ្លាស់ប្តូរបុគ្គលិកមួយចំនួនឱ្យទៅធ្វើការនៅការិយាល័យសាខានានា ក្នុងរាជធានីភ្នំពេញ ដើម្បីបង្កើនគម្លាតសង្គម ហើយយើងខ្ញុំក៏បានអនុវត្តយ៉ាងតឹងរ៉ឹងនូវវិធានសុខាភិបាលស្តីពីការបង្ការការឆ្លងជំងឺកូវីដ-១៩ ដែលចេញដោយក្រសួងសុខាភិបាល។

ដើម្បីសុវត្ថិភាពបុគ្គលិកនិងអតិថិជន យើងខ្ញុំលើកទឹកចិត្តឱ្យពួកគាត់ធ្វើសេវាកម្មធនាគារតាមរយៈ ម៉ាស៊ីនអេធីអឹម និងសេវាធនាគារចល័ត។ ប្រសិនបើអតិថិជនត្រូវការមកជួបយើងខ្ញុំដោយផ្ទាល់ យើងខ្ញុំធ្វើឱ្យប្រាកដថា យើងខ្ញុំបានធ្វើតាមវិធានសុខាភិបាលស្តីពីការបង្ការការឆ្លងជំងឺ កូវីដ-១៩ របស់ក្រសួងសុខាភិបាល ដើម្បីរក្សាសុវត្ថិភាពជូនអ្នករាល់គ្នា។ គ្រប់សាខាទាំងអស់កំពុងធ្វើប្រតិបត្តិការសេវាកម្មដូចធម្មតា ប៉ុន្តែយើងខ្ញុំតម្រូវឱ្យអតិថិជន និងបុគ្គលិក អនុវត្តនូវសេចក្តីណែនាំស្តីពីការរក្សាគម្លាតសុវត្ថិភាព និងការចេញចូលការិយាល័យ (លាងដៃ ត្រួតពិនិត្យសីតុណ្ហភាព ពាក់របាំងមុខ និងស្កេន QR កូដ របស់ក្រសួងសុខាភិបាល)។

ការថយចុះនៃកំណើនសេដ្ឋកិច្ចសកលនិងកម្ពុជា គឺបណ្តាលមកពីផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩។ វាតម្រូវឱ្យមានអន្តរាគមន៍ និងកិច្ចខិតខំប្រឹងប្រែងជាច្រើនពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដើម្បីឱ្យមាននូវផែនការបន្តនិរន្តរភាពអាជីវកម្មច្បាស់លាស់ និងអនុវត្តឱ្យមានប្រសិទ្ធភាព។

ទោះយ៉ាងណា ប្រាសាក់នៅតែរក្សាជំហរជាអ្នកនាំមុខក្នុងទីផ្សារ ជាមួយនឹងលទ្ធផលដ៏រឹងមាំ គិតត្រឹមខែធ្នូ ឆ្នាំ២០២០។ ខាងក្រោមនេះគឺជាលទ្ធផលសំខាន់ៗសង្ខេបនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០៖

- ទ្រព្យសកម្មសរុប ៣.៦១៦ លានដុល្លារអាមេរិក
- សម្ពៀតឥណទានសរុប ២.៩៧៩ លានដុល្លារអាមេរិក ជាមួយនឹងអតិថិជនសរុបចំនួន ៤៤៣ ពាន់នាក់
- អនុបាតឥណទានមិនដំណើរការមានចំនួន១,៣៧%
- សមតុល្យប្រាក់បញ្ញើសន្សំ ២.០៦១ លានដុល្លារអាមេរិក ដែលមានគណនីសរុបចំនួន ៨០០ ពាន់គណនី
- អនុបាតចំណេញធៀបនឹងមូលធនជាមធ្យមមានចំនួន ២៣,៥៣% និងអនុបាតចំណេញធៀបនឹងទ្រព្យសកម្មជាមធ្យមមានចំនួន ៣,២៥%
- បណ្តាញការិយាល័យគ្របដណ្តប់ទូទាំង ២៥ រាជធានី-ខេត្ត ចំនួន ១៨២ កន្លែង ម៉ាស៊ីនអេធីអឹមចំនួន ១៤១គ្រឿង ជាមួយនឹងចំនួនបុគ្គលិកសរុប ៩.០៤២ នាក់។

ទោះស្ថិតក្នុងបរិបទនៃការភ័យខ្លាចចំពោះជំងឺកូវីដ-១៩ ប្រាសាក់ នៅតែអាចកៀរគរមូលនិធិបន្ថែមបានចំនួន ១២៧.២ ពាន់លានរៀល (៣១.១៨ លានដុល្លារអាមេរិក) តាមរយៈការបោះផ្សាយមូលបត្របំណុលសាជីវកម្ម សម្រាប់ការបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅផ្សារមូលបត្រកម្ពុជា។ នេះបង្ហាញពីការជឿទុកចិត្តយ៉ាងមុតមាំពីអ្នកវិនិយោគិន និងសាធារណជនទៅលើប្រាសាក់ ។

ប្រាសាក់ នៅតែបន្តវិនិយោគលើអាជីវកម្មរបស់ខ្លួន ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា បុគ្គលិក និងស្លាកសញ្ញា ដើម្បីផ្តល់នូវបទពិសោធន៍ដែលផ្តោតលើអតិថិជនជាសំខាន់ និងជួយអតិថិជនឱ្យមានទំនុកចិត្តអំពីអនាគតហិរញ្ញវត្ថុរបស់ពួកគាត់។ យើងខ្ញុំក៏នឹងបន្តថែរក្សានូវការគ្រប់គ្រងហានិភ័យដ៏រឹងមាំ និងផ្តោតទៅលើភាពប្រសើរបំផុតនៃប្រតិបត្តិការ ខណៈពេលដែលការជំរុញវប្បធម៌តែមួយ និងការរួមបញ្ចូលរបស់យើងខ្ញុំ ក្នុងការនាំមកនូវអ្វីដែលល្អបំផុតសម្រាប់អតិថិជននិងភាគីពាក់ព័ន្ធ។

ឆ្នាំ២០២០ គឺជាឆ្នាំដែលបង្កការលំបាកបំផុតសម្រាប់អាជីវកម្មទាំងអស់ និងជីវិតមនុស្សគ្រប់គ្នា។ ទោះបីជាយ៉ាងនេះក្តី យើងខ្ញុំជឿជាក់ថាយុទ្ធសាស្ត្រ ការខិតខំ និងបុគ្គលិកដែលមានការប្តេជ្ញាចិត្តខ្ពស់របស់យើងខ្ញុំ នឹងទទួលបាននូវវឌ្ឍនភាពដ៏ល្អសម្រាប់ឆ្នាំនេះ។ ប្រាសាក់ នឹងនៅតែស្ថិតក្នុងជំហររឹងមាំដើម្បីអនុវត្តតាមគោលដៅលទ្ធផលរយៈពេលមធ្យម និងបង្កើតគុណតម្លៃសម្រាប់ភាគីពាក់ព័ន្ធក្នុងរយៈពេលវែង។

ជំនួសមុខឱ្យគណៈគ្រប់គ្រងនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់គ្រប់គ្រងគ្រប់លំដាប់ថ្នាក់ និងបុគ្គលិកប្រាសាក់ទាំងអស់ចំពោះការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញការងារ អរគុណចំពោះក្រុមប្រឹក្សាភិបាលក្នុងការគាំទ្រនិងការផ្តល់ដំបូន្មាន និងអរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា និយ័តកម្ម ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជា (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា) និងផ្សារមូលបត្រកម្ពុជា រួមជាមួយនឹងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ដែល តែងតែគាំទ្រប្រាសាក់។

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

**ស៊ឹម សេនាជាតិ**

ប្រធាននាយកប្រតិបត្តិ

# មាតិកា


ទស្សនវិស័យ និង បេសកម្ម ........ i

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ iii

ស្ថិតិសង្ខេបប្រចាំឆ្នាំអំពីលទ្ធផលប្រតិបត្តិការ ........ iv

ក្រុមប្រឹក្សាភិបាល ........ v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ vi

សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ ........ viii

ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ខ. លក្ខណៈនៃធុរកិច្ច ........ ១

គ. ព្រឹត្តិការណ៍សំខាន់ៗរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ២

ឃ. ស្ថានភាពទីផ្សារ ........ ៣

ង. ស្ថានភាពប្រកួតប្រជែង ........ ៤

ច. ផែនការអនាគត ........ ៤

ឆ. កត្តាហានិភ័យ ........ ៤

ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ៦

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ........ ៦

ខ. រចនាសម្ព័ន្ធចំណូល ........ ៦

ផ្នែកទី ៣- ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម ........ ៧

ក. អង្គការលេខ ........ ៧

ខ. ក្រុមប្រឹក្សាភិបាល ........ ៨

គ. បុគ្គលិកជាន់ខ្ពស់ ........ ៨

ផ្នែកទី ៤ - ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ៩

ក. ព័ត៌មានអំពីមូលបត្រ ........ ៩

ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ ........ ១០

គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ) ........ ១០

ឃ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពីចំនួន ៥% ដល់តិចជាង ៣០%) .... ១១

ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) ១១

ផ្នែកទី ៥ - របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ........ ១២

ផ្នែកទី ៦ - របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ ............ ១៥

ផ្នែកទី ៧ - ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍ ............ ១៦

ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ ............ ១៦

ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលជាន់ខ្ពស់ ............ ១៦

គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម ............ ១៦

ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ ............ ១៦

ង. ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហូលឌីង របស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះ កើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ ............ ១៧

ច. ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល...... ១៧

ឆ. ប្រតិបត្តិការសំខាន់ៗ ជាមួយអភិបាលដែលកាន់មុខតំណែងណាមួយ នៅក្នុងសមាគម ឬ អង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ ............ ១៧

ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ............ ១៧

ផ្នែកទី ៨ - ការពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង ............ ១៨

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ............ ១៨

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ............ ២១

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ............ ២២

ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ............ ២២

ង. ផលប៉ះពាល់នៃអតិផរណា ............ ២៨

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ............ ២៨

ផ្នែកទី ៩ - ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន (ប្រសិនបើមាន) ............ ៣០

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ............ ៣១

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក** |
| ជាអក្សរឡាតាំង | PRASAC Microfinance Institution Plc. |
| លេខកូដស្តង់ដារ | KH២០០០១៣១A៤២ |
| ទីស្នាក់ការ | អគារលេខ២១២ ផ្លូវ២៧១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៩៩៩ ៩១១ / +៨៥៥ ៨៦ ៩៩៩ ៩១១ |
| លេខទូរសារ | +៨៥៥ ២៣ ២១៦ ៣៦២ |
| វេបសាយត៍ | www.prasac.com.kh |
| អ៊ីម៉ែល | info@prasac.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០១១៥៧ កាលបរិច្ឆេទ៖ ១១ កញ្ញា ២០១១ |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ម.ហ ១០ ចេញដោយ៖ ធនាគារជាតិនៃកម្ពុជា កាលបរិច្ឆេទ៖ ១៩ តុលា ២០១២ |
| សេចក្តីសម្រេចអនុញ្ញាតនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៧/២០គ.ម.ក/ស.ស.រ កាលបរិច្ឆេទ៖ ៣០ មីនា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក ស៊ឹម សេនាជាតិ |

## ខ. លក្ខណៈនៃធុរកិច្ច

ប្រាសាក់ មានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ពីធនាគារជាតិនៃកម្ពុជា និងធ្វើប្រតិបត្តិការអស់រយៈពេល ២៥ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារនៅកម្ពុជា។ បច្ចុប្បន្ននេះ ប្រាសាក់ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំជាងគេ បើគិតពីទ្រព្យសកម្ម សម្ពៀតឥណទាន គុណភាពឥណទាន ប្រាក់ចំណេញ ប្រាក់បញ្ញើពីអតិថិជន និងឈរលំដាប់កំពូលក្នុងចំណោមគ្រឹះស្ថានធនាគារធំៗចំនួន ៥ នៅក្នុងប្រទេសកម្ពុជា។

ប្រាសាក់ ផ្តល់សេវាហិរញ្ញវត្ថុដ៏សម្បូរបែប មានជាអាទិ៍សេវាឥណទាន ប្រាក់បញ្ញើសន្សំ ទូទាត់វិក្កយបត្រភ្លើង ទូទាត់វិក្កយបត្រទឹក បង់ថ្លៃសិក្សា ផ្ទេរប្រាក់តាមលេខសម្ងាត់ ផ្ទេរប្រាក់ ប្តូរប្រាក់ ទិញកាតទូរស័ព្ទ ខេមបូខានស៊ែរស្វីច (CSS) សេវាទូទាត់ហ៊េស សេវាទូទាត់បាគង សេវាផ្ទេរមូលនិធិភ្លាមៗ សេវាបើកប្រាក់បៀវត្ស អេធីអឹម ម៉ាស៊ីនដាក់ប្រាក់ សេវាធនាគារចល័ត (Mobile Banking ឬ Internet Banking) ម៉ាស៊ីនឆូតកាត សេវាបញ្ជាក់សមតុល្យគណនី និងសេវាហិរញ្ញវត្ថុដទៃផ្សេងៗទៀត។

ជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេដោយមានទ្រព្យសកម្មសរុបចំនួន ៣.៦១៦ លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ប្រាសាក់មានបណ្តាញការិយាល័យសាខាធំជាងគេលំដាប់ទី២ ដោយមានសាខាចំនួន ១៨២ ទីតាំងនៅក្នុងប្រទេសកម្ពុជា។ ប្រាសាក់ មានប្រតិបត្តិការហិរញ្ញវត្ថុដ៏រឹងមាំ ការបម្រើសេវាកម្មប្រកប ដោយវិជ្ជាជីវៈ និងមានប្រព័ន្ធធនាគារស្នូលទំនើបប្រកបដោយតម្លាភាព សម្រាប់បំពេញតម្រូវការរបស់អតិថិជន និងសាធារណជន។

## គ. ព្រឹត្តិការណ៍សំខាន់ៗរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ចាប់តាំងពីបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ប្រាសាក់ បានឆ្លងកាត់ដំណាក់កាលអភិវឌ្ឍន៍ជាច្រើន។ ខាងក្រោមនេះជាព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើងក្នុងឆ្នាំ ២០២០ ៖

- ប្រាសាក់ ដាក់ឱ្យប្រើប្រាស់មុខងារ «ស្កេន-ទូទាត់ តាម QR កូដ» នៅក្នុងកម្មវិធី PRASAC Mobile Banking ក្នុងទូរស័ព្ទដៃ ដែលអនុញ្ញាតឱ្យអតិថិជនអាចទូទាត់ទំនិញនិងសេវាបានភ្លាមៗនៅតាមហាងនានាយ៉ាងងាយស្រួលដោយមិនចាំបាច់ប្រើសាច់ប្រាក់ និងមិនអស់កម្រៃសេវា។ ហើយមុខងារនេះដែរសម្រួលដល់អតិថិជនប្រាសាក់ទាំងអស់អាចគ្រប់គ្រងការផ្ទេរប្រាក់ទៅកាន់ដៃគូជំនួញ និងសាច់ញាតិបានរហ័សដោយគ្រាន់តែស្កេន QR កូដ។
- ប្រាសាក់ បានដាក់សម្ពោធអគារបណ្ណាល័យថ្មីមួយខ្នង ឧបត្ថម្ភថវិកាដោយប្រាសាក់ និងមូលនិធិ CVC នៅសាលាបឋមសិក្សាសំរោង ស្ថិតក្នុងភូមិចេក ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដើម្បីចូលរួមលើកកម្ពស់វិស័យអប់រំ និងបណ្តុះ វប្បធម៌អាន។
- ប្រាសាក់ បានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធកម្រិតមាស ពីអគ្គនាយកដ្ឋានពន្ធដារ ដែលបង្ហាញឱ្យឃើញពីការប្រកាន់ខ្ជាប់របស់ខ្លួនក្នុងកាតព្វកិច្ចបង់ពន្ធស្របតាមគោលការណ៍ និងបទប្បញ្ញត្តិសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។
- ប្រាសាក់ ទទួលបានភាគទុនិកធំថ្មី គឺ «ធនាគារ ខេប៊ី គូកមីន (KB Kookmin Bank)» លើការទិញភាគហ៊ុនចំនួន ៧០% របស់ប្រាសាក់។
- ប្រាសាក់ បានចូលរួមក្នុង «គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម» ដែលជាគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងផ្តល់កម្ចីដែលមានអត្រាការប្រាក់ទាប ដើម្បីជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។
- សញ្ញាបណ្ណសាជីវកម្មរបស់ ប្រាសាក់ ត្រូវបានចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា ដែលអនុញ្ញាតឱ្យចាប់ផ្តើមសកម្មភាពជួញដូរ ក្រោមនិមិត្តសញ្ញា «PRA23A» និងជាសញ្ញាបណ្ណទី ៦ ដែលត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា និងជាសញ្ញាបណ្ណទី ២ ដែលត្រូវបានធានាដោយស្ថាប័ន Credit Guarantee and Investment Facility (CGIF) ដែលជាមូលនិធិបរធនមួយនៃធនាគារអភិវឌ្ឍន៍អាស៊ី ។
- ប្រាសាក់បានផ្លាស់ប្តូរទម្រង់គតិយុត្ត និងនាមករណ៍ពី «ប្រាសាក់ ម៉ាយក្រូហ្វាយនែន អ៊ិនស្ទីធ្យូសិន លីមីតធីត ហៅកាត់ថា ប្រាសាក់ អិមអេហ្វអាយ អិលធីឌី» ទៅជា «គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ហៅកាត់ថា ប្រាសាក់ អិមអេហ្វអាយ ម.ក.» ដែលទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម។
- ប្រាសាក់ បានដាក់ឱ្យដំណើរការសេវាផ្តល់ប័ណ្ណអេធីអឹមភ្លាមៗ ក្នុងគោលបំណងធ្វើឱ្យដំណើរការនៃការផ្តល់ប័ណ្ណនេះកាន់តែមានភាពងាយស្រួល សាមញ្ញ និងលឿនរហ័ស និងចូលរួមជំរុញបរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា។
- ប្រាសាក់ បានបើកឱ្យដំណើរការការិយាល័យសាខាចំនួន ២ បន្ថែមទៀតគឺ សាខាព្រៃផ្តៅ នៅខេត្តកំពង់ស្ពឺ និងសាខាក្រុងអង្គរ នៅខេត្តសៀមរាប។

- ប្រាសាក់ ទទួលបានអនុបំណុលក្នុងទឹកប្រាក់ ៥០ លានដុល្លារអាមេរិក សម្រាប់រយៈពេល ៧ ឆ្នាំ និងកិច្ចសន្យាផ្តល់ទុនក្នុងទឹកប្រាក់ ១០០ លានដុល្លារអាមេរិក សម្រាប់រយៈពេល ៣ ឆ្នាំ ពីធនាគារ ខេប៊ី គូកមីន ដែលជាម្ចាស់ភាគទុនិកថ្មី ។
- នៅខែមិថុនា ឆ្នាំ២០២០ ប្រាសាក់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានជាក្រុម ដែលបានបង្កើតឡើងក្នុងរយៈពេលពី ៣ ទៅ ៥ ឆ្នាំក្នុងទឹកប្រាក់ ៩៥ លានដុល្លារអាមេរិក ជាមួយក្រុមធនាគារដែលដឹកនាំដោយក្រុមហ៊ុន TAISHIN INTERNATIONAL BANK CO ., LTD ដើម្បីគាំទ្រដល់សកម្មភាពផ្តល់ប្រាក់កម្ចីរបស់ខ្លួន។
- ប្រាសាក់ បានពង្រីកការផ្តល់សេវាទូទាត់វិក្កយបត្រអគ្គិសនីកម្ពុជា ដល់ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ ក្រុងព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តមណ្ឌលគិរី។
- ប្រាសាក់ ផ្តល់សេវាទូទាត់ឆ្លងធនាគារយុគសម័យថ្មីតាម «ប្រព័ន្ធបាគង» ក្នុងគោលបំណងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ នៅកម្ពុជាផងដែរ។
- ប្រាសាក់ បានដាក់ឱ្យដំណើរការសេវាទូទាត់វិក្កយបត្រទឹកស្អាតនៅខេត្តត្បូងឃ្មុំ។
- ប្រាសាក់ បានសម្រេចលទ្ធផលថ្មីមួយ គឺសមតុល្យប្រាក់បញ្ញើសន្សំសរុបមានចំនួន ២ ប៊ីលានដុល្លារ និងមានគណនីអតិថិជនចំនួន ៦២៧.០០០ អតិថិជនប្រាក់បញ្ញើសន្សំ។
- ប្រាសាក់បានបរិច្ចាគថវិកាចំនួន ២០០ លានរៀលដល់សម្តេចតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយគ្រោះទឹកជំនន់។
- ប្រាសាក់បានចាប់ផ្តើមយុទ្ធនាការមួយដែលមានឈ្មោះថា "ការរៃអង្គាសថវិកាសម្រាប់ទិញវ៉ាក់សាំងសម្រាប់ប្រទេសកម្ពុជា" ដើម្បីកៀរគរថវិកា ដើម្បីទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដើម្បីជួយសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជា។
- ប្រាសាក់បានបរិច្ចាគថវិកាចំនួន ២.០០០.០០០.០០០រៀល (ពីរប៊ីលានរៀល) ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដើម្បីចាក់ជូនប្រជាជនកម្ពុជាដោយឥតគិតថ្លៃ ក្នុងបុព្វហេតុការពារអាយុជីវិតប្រជាជន និងលើកកម្ពស់ សុខភាពសាធារណៈ។
- នៅខែធ្នូឆ្នាំ ២០២០ ប្រាសាក់បានចុះកិច្ចសន្យាផ្តល់ប្រាក់កម្ចីសម្រាប់រយៈពេល ៣ ឆ្នាំក្នុងទឹកប្រាក់ ១៥០ លានដុល្លារអាមេរិក ជាមួយធនាគារ ខេប៊ី គូកមីន (KB Kookmin Bank) សាខាហុងកុង សម្រាប់គាំទ្រសកម្មភាពផ្តល់ប្រាក់កម្ចីរបស់ខ្លួន។

## ឃ. ស្ថានភាពទីផ្សារ

បច្ចុប្បន្ន ប្រាសាក់ ឈរលំដាប់ទី ១ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងជាគ្រឹះស្ថាន ១ ក្នុងចំណោមធនាគារធំៗទាំង ៥ ក្នុងវិស័យធនាគារនៅកម្ពុជា។ ដើម្បីពង្រឹងជំហរដ៏រឹងមាំនេះ ប្រាសាក់ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាលើការអភិវឌ្ឍផលិតផល និងសេវាកម្មថ្មីៗ ដូចខាងក្រោម៖

- សេវាឥណទានដែលសមស្របនឹងសហគ្រាសធុនតូចបំផុត ធុនតូច និងធុនមធ្យម ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា
- ការអភិវឌ្ឍសេវាធនាគារកាន់តែច្រើន ដើម្បីទាក់ទាញអតិថិជនច្រើនប្រភេទ
- បន្តការអភិវឌ្ឍសេវាដែលប្រើបច្ចេកវិទ្យាទំនើប ជាពិសេសសេវាធនាគារចល័តប្រាសាក់ (Mobile Banking and Internet Banking) និងសេវាផ្សេងទៀត
- បន្តការអភិវឌ្ឍការទូទាត់ដោយមិនប្រើសាច់ប្រាក់ (ប្រើ QR កូដ) និងចាប់ដៃគូសហការជាមួយបណ្តាហាងទំនិញ និងសេវា ដើម្បីផ្តល់ភាពងាយស្រួលជូនអតិថិជន និងជំរុញបរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា

- ពង្រីកការិយាល័យសាខា និងបណ្តាញម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនដាក់ប្រាក់
- ពង្រឹងគុណភាពសេវាកម្ម ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន។

## ខ. ស្ថានភាពប្រកួតប្រជែង

ការប្រកួតប្រជែងក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុមានលក្ខណៈខ្លាំងក្លា។ មានធនាគារពាណិជ្ជចំនួន ៥២ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៨១ ដែលក្នុងនោះក៏មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើផងដែរ ខណៈដែលធនាគារឯកទេសបានកើនដល់ ១៤ គិតត្រឹមថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២០។

ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ដែលយើងបានប្រកួតប្រជែង ជាទូទៅវិវត្តទៅរកភាពខ្លាំង។ យើងក៏បានជួបប្រទះនូវការប្រកួតប្រជែងនៅក្នុងភូមិសាស្ត្រ និងចំណែកទីផ្សារអាជីវកម្មមួយចំនួនផងដែរពីស្ថាប័នថ្មីៗ។ ថ្វីបើការប្រកួតប្រជែងមានការកើនឡើង យើងនៅតែរក្សាបានជំហរនាំមុខគេ ហើយបានធ្វើការវិនិយោគសំខាន់ៗលើសមត្ថភាពបុគ្គលិក ដំណើរការ និងបច្ចេកវិទ្យា ដើម្បីបំពេញតម្រូវការដល់អតិថិជនថ្មី និងចាស់តាមគន្លងរបស់យើង។

ដោយប្តេជ្ញាចិត្តក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុដែលជាទីទុកចិត្ត ប្រាសាក់ ទទួលបានកេរ្តិ៍ឈ្មោះជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដ៏គួរឱ្យជឿជាក់ ជាមួយនឹងលទ្ធផលហិរញ្ញវត្ថុយ៉ាងរឹងមាំ និងកំណើនប្រកបដោយនិរន្តរភាព។ យើងមានលទ្ធភាពផ្តល់ជូនផលិតផលនិងសេវាហិរញ្ញវត្ថុសម្បូរបែបដល់បណ្តាសហគ្រាសធុនតូចបំផុត តូច និងមធ្យម ទន្ទឹមនឹងការធ្វើឱ្យខ្លួនយើងក្លាយជាអ្នកផ្តល់សេវាធនាគារដែលគួរឱ្យទុកចិត្ត ងាយស្រួលប្រើប្រាស់ ទំនើប និងទទួលបានការប្រើប្រាស់បានយ៉ាងងាយស្រួល។

## ច. ផែនការអនាគត

ដោយការសម្លឹងឆ្ពោះទៅមុខ វិស័យសេវាកម្មហិរញ្ញវត្ថុនឹងត្រូវបានកែលម្អបន្ថែមទៀតតាមរយៈនវានុវត្តន៍ និងការផ្លាស់ប្តូរនៃបច្ចេកវិទ្យាដ៏លឿនរហ័ស។ យើងបានរៀបចំបង្កើនសមត្ថភាពរបស់មជ្ឈមណ្ឌលទិន្នន័យ មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ សន្តិសុខតាមប្រព័ន្ធអ៊ិនធឺណិត និងហានិភ័យនៃការក្លែងបន្លំ ព្រមទាំងទិដ្ឋភាពនៃបទប្បញ្ញត្តិដែលតែងតែប្រែប្រួល។ យើងនឹងបន្តពង្រឹងការអនុវត្តគោលការណ៍ណែនាំស្តីពីសន្តិសុខព័ត៌មានវិទ្យារបស់ធនាគារជាតិ។

ប្រាសាក់ នឹងបន្តវិនិយោគលើអាជីវកម្ម ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា ធនធានមនុស្ស និងនាមករណ៍របស់ខ្លួន ដើម្បីផ្តល់នូវបទពិសោធន៍ដ៏ល្អជូនអតិថិជន និងជ្រោមជ្រែងដល់ពួកគាត់ឱ្យទទួលបានទំនុកចិត្តលើអនាគតហិរញ្ញវត្ថុរបស់ពួកគាត់។ យើងរក្សានូវវប្បធម៌ការពារហានិភ័យឱ្យបានរឹងមាំ និងផ្តោតលើឧត្តមភាពនៃប្រតិបត្តិការ ព្រមទាំងលើកកម្ពស់វប្បធម៌នៃការធ្វើបរិយាប័ន្នដ៏លេចធ្លោ ដើម្បីនាំមកនូវអ្វីដែលល្អបំផុតសម្រាប់អតិថិជន និងភាគីពាក់ព័ន្ធទាំងអស់របស់យើង។

## ឆ. កត្តាហានិភ័យ

### ១. ការវិភាគ

ក្នុងឆ្នាំ២០២០ ប្រាសាក់បានមើលឃើញហានិភ័យចម្បងចំនួនពីរ ដែលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា និងគុណភាពផលប័ត្ររបស់ប្រាសាក់ ក៏ដូចជាបុគ្គលិករបស់ខ្លួនផង។ ហានិភ័យចម្បងៗ ចំនួនពីរ មានដូចខាងក្រោមនេះ៖

- **កត្តាកូវីដ-១៩:** កូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ចរបស់កម្ពុជាថយចុះ ២% (ADB) ក្នុងនោះវិស័យទេសចរណ៍មានផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ គឺខ្ពស់ជាងវិស័យដទៃទៀត ដូចជាវិស័យអាជីវកម្ម សំណង់ ឬកសិកម្ម។ ក្នុងនោះ ធនាគារជាតិ

នៃកម្ពុជា បានលើកទឹកចិត្តឱ្យគ្រប់ស្ថាប័នហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាទាំងអស់ ឱ្យធ្វើកម្ចីរៀបចំឡើងវិញ (restructure loan) និងផ្តល់លក្ខខណ្ឌងាយស្រួលដល់អតិថិជនក្នុងការសងត្រឡប់។

- **និយោជិក:** និយោជិក គឺជាទ្រព្យសម្បត្តិមានតម្លៃបំផុតរបស់ស្ថាប័ន ហើយប្រាសាក់តែងតែយកចិត្តទុកដាក់ថែទាំ ការពារ និងផ្តល់អាទិភាពចំពោះនិយោជិកមុនគេក្នុងការទប់ស្កាត់កុំឱ្យឆ្លង។

## ២. ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់

បើទោះបីកត្តាហានិភ័យសំខាន់ៗទាំង២កើតមានឡើងក៏ដោយ ក៏ប្រាសាក់នៅតែអាចគ្រប់គ្រង និងកាត់បន្ថយហានិភ័យទាំងនោះ បានដោយយោងលើគោលនយោបាយរបស់ស្ថាប័ន ដែលបង្កើតឡើងតាំងពីមុនការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងប្រទេស ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសធនាគារជាតិនៃកម្ពុជា។ ការចាត់វិធានការរបស់ស្ថាប័នមានដូចខាងក្រោម៖

- **ការគ្រប់គ្រងហានិភ័យឥណទាន**
  - រឹតបន្តឹងគោលការណ៍ និងជាពិសេសការកំណត់លក្ខណៈវិនិច្ឆ័យរបស់អតិថិជនកម្ចី
  - រឹតបន្តឹងលើការវិភាគមុខរបរ/ទ្រព្យដាក់ធានារបស់អតិថិជន
  - រឹតបន្តឹងលើការអនុម័តកម្ចី
- **ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ**
  - ដាក់ចេញនូវការណែនាំ ការការពារជំងឺកូវីដ-១៩ដល់បុគ្គលិក
  - ធ្វើការតាមដានសុខភាពរបស់បុគ្គលិកជាប្រចាំថ្ងៃ
  - ត្រួតពិនិត្យអនាម័យនៅតាមសាខាជាប្រចាំថ្ងៃ
  - បំបែកបុគ្គលិកឱ្យទៅធ្វើការនៅតាមសាខា
  - ការធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ ប្រសិនបើនិយោជិតមានអាការៈផ្តាសាយ ឬក៏បានធ្វើដំណើរទៅកាន់តំបន់ដែលមានការឆ្លងជំងឺ
  - ណែនាំដល់បុគ្គលិកទាំងអស់ឱ្យពាក់ម៉ាស់ជាប្រចាំនៅក្នុងសាលបម្រើអតិថិជន
  - ធ្វើការវាស់កម្តៅមុនពេលអនុញ្ញាតឱ្យចូលការិយាល័យ
  - លាងសម្អាតដៃជាមួយអាល់កុល
  - មិនអនុញ្ញាតឱ្យមានការជួបជុំជាក្រុម ដែលមានសមាជិកចូលរួមច្រើន
  - ធ្វើការប្រជុំ/ការបង្រៀនតាម Zoom។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

| លទ្ធផលសំខាន់ៗសម្រេចបាន | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|
| **សេវាឥណទាន** | | |
| ចំនួនអតិថិជនសេវាឥណទាន | ៤៤២.៨៣៣ | ៤១៧.០៤៤ |
| សម្ពៀតឥណទានសរុប (លានរៀល) | ១២.០៤៨.៣៥៦ | ១០.០៥៨.០១៩ |
| **សេវាបញ្ញើសន្សំ** | | |
| ចំនួនអតិថិជនសេវាបញ្ញើសន្សំ | ៦២៧.១៨៨ | ៦០០.២០៤ |
| សមតុល្យប្រាក់បញ្ញើសន្សំសរុប (លានរៀល) | ៨.៣៣៨.២១៩ | ៧.២៨៨.២៧២ |
| **ផ្សេងៗ** | | |
| ចំនួនការិយាល័យ | ១៨២ | ១៨០ |
| ចំនួនបុគ្គលិក | ៩.០៤២ | ៩.០៩១ |
| ចំនួនម៉ាស៊ីនឆូតកាត | ៥១៤ | ៥០៩ |
| ចំនួនម៉ាស៊ីនអេធីអឹម | ១៤១ | ១៣៥ |
| ចំនួនប័ណ្ណអេធីអឹមកំពុងដំណើរការ | ៥៦.០៦០ | ៥៧.៨៣៤ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័តកំពុងដំណើរ | ២១.២១៣ | ១៥.៤៣១ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ២០២០ | | ២០១៩ | |
|---|---|---|---|---|---|
| | | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ១.៧៥៤.៦៦៦ | ៩៦,១១% | ១.៤៤៣.៥៤៧ | ៩២,២៥% |
| ២ | ចំណូលកម្រៃជើងសា | ២៨.០៤៥ | ១,៥៤% | ៧៣.៩៣៤ | ៤,៧២% |
| ៣ | ចំណូលផ្សេងៗ | ៤២.៨៤៧ | ២,៣៥% | ៤៧.៣៨៤ | ៣,០៣% |
| | **ចំណូលសរុប** | **១.៨២៥.៥៥៨** | **១០០%** | **១.៥៦៤.៨៦៥** | **១០០%** |

## ក. អង្គការលេខ



មហាសន្និបាតភាគទុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មការសវនកម្ម
គណៈកម្មការគ្រប់គ្រងហានិភ័យ
ប្រធាននាយកប្រតិបត្តិ
គណៈកម្មការតែងតាំង និងតម្លៃការ
នាយកដ្ឋានសវនកម្មផ្ទៃក្នុង
សវនកម្មភូមិភាគ និងសាខា
សវនកម្មការិយាល័យកណ្តាល
សវនកម្មព័ត៌មានវិទ្យា
ធានាគុណភាព និងអភិវឌ្ឍន៍សវនកម្ម
នាយកដ្ឋានប្រតិបត្តិតាម
ប្រតិបត្តិតាមបទប្បញ្ញត្តិ
ប្រឆាំងការសម្អាតប្រាក់
ប្រធានគ្រប់គ្រងហានិភ័យ
នាយកដ្ឋានគ្រប់គ្រងហានិភ័យ
ហានិភ័យឥណទាន
ហានិភ័យប្រតិបត្តិការ
ហានិភ័យហិរញ្ញវត្ថុ
អនុប្រធាននាយកប្រតិបត្តិ
គណៈកម្មការនាយកប្រតិបត្តិ
គណៈកម្មការឥណទាន
គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល
គណៈកម្មការគ្រប់គ្រង ៧ផ្សេងទៀត
អគ្គនាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការ
នាយកដ្ឋានប្រតិបត្តិការ
ប្រតិបត្តិការទូទាត់
ប្រតិបត្តិការហិរញ្ញកិច្ច
គាំទ្រប្រតិបត្តិការដោយប្រយោល
គាំទ្រប្រតិបត្តិការដល់ទីកន្លែង
ដំណើរការប្រតិបត្តិការនៅការិយាល័យ
អភិវឌ្ឍន៍នីតិវិធីប្រតិបត្តិការ
ប្រធានគ្រប់គ្រងព័ត៌មានវិទ្យា
នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធធនាគារស្នូល
អភិវឌ្ឍន៍កម្មវិធី
គ្រប់គ្រងប្រព័ន្ធព័ត៌មាន
គ្រប់គ្រងប្រព័ន្ធធនាគារស្នូល
គ្រប់គ្រង និងរក្សាទិន្នន័យ
គាំទ្រប្រព័ន្ធធនាគារស្នូល
នាយកដ្ឋានឌីជីថលបែងចែក
គ្រប់គ្រងប្រព័ន្ធធនាគារអេឡិចត្រូនិក
គាំទ្រប្រតិបត្តិការប្រព័ន្ធធនាគារ អេឡិចត្រូនិក
គ្រប់គ្រងម៉ាស៊ីនដកប្រាក់ និងម៉ាស៊ីនឆូតកាត
នាយកដ្ឋានព័ត៌មានវិទ្យា
គ្រប់គ្រងរដ្ឋបាលប្រព័ន្ធព័ត៌មានវិទ្យា
គ្រប់គ្រងរដ្ឋបាលប្រព័ន្ធបណ្តាញ ព័ត៌មានវិទ្យា
គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ
សន្តិសុខបច្ចេកវិទ្យាព័ត៌មាន
អគ្គនាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ
នាយកដ្ឋានហិរញ្ញវត្ថុ
ត្រួតពិនិត្យហិរញ្ញវត្ថុ
គណនេយ្យគ្រប់គ្រង
គណនេយ្យហិរញ្ញវត្ថុ
របាយការណ៍និយ័តកម្ម
ប្រតិបត្តិពន្ធ
នាយកដ្ឋានហិរញ្ញកិច្ច
ទំនាក់ទំនងអ្នកវិនិយោគ
គ្រប់គ្រងសម្ព័ន្ធធនាគារ
គ្រប់គ្រងសាច់ប្រាក់សាខា
ពាណិជ្ជកម្មហិរញ្ញកិច្ច
នាយកដ្ឋានរដ្ឋបាលទូទៅ
រដ្ឋបាលទូទៅ
គ្រប់គ្រងការិយាល័យ
គ្រប់គ្រងអចលនទ្រព្យ
លទ្ធកម្ម
អគ្គនាយកដ្ឋានគ្រប់គ្រងអាជីវកម្ម
នាយកដ្ឋានឥណទាន
គាំទ្រការផ្តល់ឥណទាន
ពិនិត្យវិភាគសម្លៀត និងរបាយការណ៍ឥណទាន
ត្រួតពិនិត្យឥណទាន
រដ្ឋបាលឥណទាន
គ្រប់គ្រងឥណទានមិនដំណើរការ
ឥណទានសហគ្រាសខ្នាតតូច និងមធ្យម
ភូមិភាគ
សាខា
នាយកដ្ឋានសេវាធនាគារ
គាំទ្រការលក់ប្រាក់បញ្ញើសន្សំ
គាំទ្រការលក់សេវាធនាគារ
អគ្គនាយកដ្ឋានគ្រប់គ្រងទីផ្សារ
នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល
អភិវឌ្ឍន៍ផលិតផលឥណទាន
អភិវឌ្ឍន៍ផលិតផលសេវាធនាគារ
នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង
ផ្សព្វផ្សាយ និងទំនាក់ទំនង
ស្រាវជ្រាវ និងអភិវឌ្ឍន៍
កិច្ចការងារសង្គម
សេវាអតិថិជន
អគ្គនាយកដ្ឋានគ្រប់គ្រងធនធានមនុស្ស
នាយកដ្ឋានបុគ្គលិក
ជ្រើសរើសបុគ្គលិក
គ្រប់គ្រងការងារបុគ្គលិក
គ្រប់គ្រងលទ្ធផលការងារបុគ្គលិក
ប្រាក់សំណង និងអត្ថប្រយោជន៍
ថែទាំសុខភាព
នាយកដ្ឋានបណ្តុះបណ្តាល និងអភិវឌ្ឍន៍បុគ្គលិក
បណ្តុះបណ្តាលឥណទាន
បណ្តុះបណ្តាលទូទៅ
អគ្គនាយកដ្ឋានរៀបចំផែនការ យុទ្ធសាស្ត្រ និងអាជីវកម្ម
លេខាធិការក្រុមហ៊ុន
រៀបចំផែនការយុទ្ធសាស្ត្រ និងគោលនយោបាយ
នីតិកម្ម
សន្តិសុខ
គ្រប់គ្រងគម្រោង

## ខ. ក្រុមប្រឹក្សាភិបាល

### សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | លោក Kwi Sang JUN | ប្រធានក្រុមប្រឹក្សាភិបាល | ១០ មេសា ២០២០ | ០៩ មេសា ២០២៣ |
| ២ | លោក Hak Soo Kim | អភិបាល | ១០ មេសា ២០២០ | ០៩ មេសា ២០២៣ |
| ៣ | លោក Ji Kyu JANG | អភិបាល | ១០ មេសា ២០២០ | ០៩ មេសា ២០២៣ |
| ៤ | លោក Ishara Chinthaka Nanayakkara | អភិបាល | ១០ មីនា ២០១៧ | ០៩ មេសា ២០២៣ |
| ៥ | លោក ស៊ឹម សេនាជាតិ | អភិបាល | ១០ មីនា ២០១៧ | ០៩ មេសា ២០២៣ |
| ៦ | លោក Minki Brian HONG | អភិបាល | ១០ មីនា ២០១៧ | ០៩ មេសា ២០២៣ |
| ៧ | លោក Hwan Kook KIM | អភិបាលឯករាជ្យ | ១០ មេសា ២០២០ | ០៩ មេសា ២០២៣ |
| ៨ | លោក Hana LEE | អភិបាលឯករាជ្យ | ១០ មេសា ២០២០ | ០៩ មេសា ២០២៣ |
| ៩ | លោក បៃល សក្តិភក្តី | អភិបាលឯករាជ្យ | ១០ មេសា ២០២០ | ០៩ មេសា ២០២៣ |

<u>**សម្គាល់:**</u> អភិបាលនីមួយៗ ត្រូវបានកំណត់រយៈពេល បី (៣)ឆ្នាំ គិតចាប់ពីថ្ងៃតែងតាំងរហូតដល់ក្រុមប្រឹក្សាភិបាលនោះ លាឈប់ ឬត្រូវបានដកចេញ។ ប៉ុន្តែអភិបាលនីមួយៗ អាចត្រូវបានតែងតាំងឡើងវិញ ហើយត្រូវបានកំណត់ត្រឹមរយៈពេលប្រាំបួន (៩)ឆ្នាំ តែប៉ុណ្ណោះ។

## គ. បុគ្គលិកជាន់ខ្ពស់

### សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | លោក ស៊ឹម សេនាជាតិ | ប្រុស | ប្រធាននាយកប្រតិបត្តិ |
| ២ | លោក អ៊ុំ សុផន | ប្រុស | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ |
| ៣ | លោក អ៊ុំ សមអឿន | ប្រុស | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| ៤ | លោក នាង សុខឃីម | ប្រុស | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម |
| ៥ | លោក សាយ សូនី | ប្រុស | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងទីផ្សារ |
| ៦ | លោក ជួប វាសនា | ប្រុស | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស |
| ៧ | លោក ជា ហាង | ប្រុស | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម |

<u>**សម្គាល់:**</u> ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាឧបសម្ព័ន្ធ។

# ផ្នែកទី ៤ - ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់បុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. ព័ត៌មានអំពីមូលបត្រ

### ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ)

| | |
|---|---|
| • ឈ្មោះមូលបត្រកម្មសិទ្ធិ | មិនមាន |
| • និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ | មិនមាន |
| • ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ | មិនមាន |
| • តម្លៃចារឹកក្នុងមួយឯកត្តាមូលបត្រកម្មសិទ្ធិ | មិនមាន |
| • ថ្លៃលក់ក្នុងមួយឯកត្តាមូលបត្រកម្មសិទ្ធិ (IPO Price) | មិនមាន |
| • បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ | មិនមាន |
| • មូលធនូបនីយកម្មទីផ្សារ | មិនមាន |
| • ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត | មិនមាន |

### ២. ព័ត៌មានអំពីមូលបត្របំណុល (ករណីចុះបញ្ជីលក់មូលបត្របំណុល)

| ព័ត៌មាន | បរិយាយ |
|---|---|
| ប្រភេទមូលបត្របំណុល | សញ្ញាបណ្ណសាជីវកម្មប្រាសាក់ |
| និមិត្តសញ្ញាមូលបត្របំណុល | PRA២៣A |
| កាលបរិច្ឆេទនៃការបោះផ្សាយ | ២៣ មេសា ២០២០ |
| តម្លៃសរុបនៃមូលបត្របំណុលដែលកំពុងចរាចរ | មិនមាន |
| បរិមាណមូលបត្របំណុលសរុប | ១២៧.២០០.០០០.០០០ រៀល |
| បរិមាណមូលបត្របំណុលសរុបទាំងអស់ | ១២៧.២០០.០០០.០០០ រៀល |
| ឥណប្រតិទាន | ២៣ មេសា ២០២០ |
| ការរំភាគទូទាត់គូប៉ុង | ២៣ មេសា និង ២៣ តុលា |
| អត្រាគូប៉ុង (%) | ៧,៥០% ក្នុង១ឆ្នាំ |
| តម្លៃសរុបនៃការទូទាត់គូប៉ុង | ៤.៧៧០.០០០.០០០ រៀល |
| ចំណាតថ្នាក់លទ្ធភាពសង (ប្រសិនបើមាន) | ក្រុមហ៊ុនបោះផ្សាយ បោះផ្សាយសញ្ញាបណ្ណមានបុគ្គលធានាដោយស្ថាប័ន CGIF។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ពុំមានលក្ខខណ្ឌតម្រូវឱ្យធ្វើចំណាត់ថ្នាក់ |

| | |
|---|---|
| | លទ្ធភាពសងលើសញ្ញាបណ្ណសាជីវកម្មនោះទេ ប៉ុន្តែបុគ្គលធានាតម្រូវឱ្យមានចំណាត់ថ្នាក់លទ្ធភាពសង។ ភាពខ្លាំងរបស់ស្ថាប័ន CGIF ចំពោះលទ្ធភាពនៃ ការទូទាត់សង៖<br><br>"AA/A-1+" កម្រិតសកល (រយៈពេលវែង & រយៈពេលខ្លី) ទស្សនវិស័យស្ថិរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង S&P នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨។<br><br>"gAAA/seaAAA/AAA" កម្រិតសកល/អាស៊ាន/ជាតិ ទស្សនវិស័យស្ថិរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង RAM Rating នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩<br><br>"AAA" កម្រិតជាតិទស្សនវិស័យស្ថិរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង MARC នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩<br><br>"AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាពកំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង TRIS Rating នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨<br><br>"AAA" កម្រិតជាតិទស្សនវិស័យស្ថិរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Fitch Rating នៃប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨។ |

## ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ ពុំមានការធ្វើពាណិជ្ជកម្មលើសញ្ញាបណ្ណសាជីវកម្មរបស់ប្រាសាក់ ដោយរក្សាតម្លៃដដែលនៅ ១០០.០០០ រៀលក្នុងមួយសញ្ញាបណ្ណ។

## គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | ធនាគារ KOOKMIN (KB) ខូលអិលធីឌី | សាធារណរដ្ឋកូរ៉េ | ១៦១.០០០.០០០ | ៧០% |
| **សរុប** | | | **១៦១.០០០.០០០** | **៧០%** |

## ឃ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពីចំនួន ៥% ដល់តិចជាង ៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | ក្រុមហ៊ុន LOLC INTERNATIONAL PRIVATE LIMITED | សិង្ហបុរី | ៤៨.៣០០.០០០ | ២១% |
| ២ | ក្រុមហ៊ុន THE BANK OF EAST ASIA, LIMITED | ហុងកុង | ១៤.៤៩០.០០០ | ៦,៣% |
| **សរុប** | | | **៦២.៧៩០.០០០** | **២៧,៣០%** |

## ខ. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ)

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ | ឆ្នាំ២០១៨ |
|---|---|---|---|
| ចំណេញសុទ្ធ | មិនមាន | មិនមាន | មិនមាន |
| ភាគលាភជាសាច់ប្រាក់សរុប | មិនមាន | មិនមាន | មិនមាន |
| ភាគលាភជាមូលបត្រកម្មសិទ្ធសរុប | មិនមាន | មិនមាន | មិនមាន |
| ភាគលាភផ្សេងទៀត | មិនមាន | មិនមាន | មិនមាន |
| អនុបាតនៃការបែងចែកភាគលាភ (%) | មិនមាន | មិនមាន | មិនមាន |
| ទិន្នផលភាគលាភ (%) | មិនមាន | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ | មិនមាន | មិនមាន | មិនមាន |

# ផ្នែកទី ៥ - របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

## ១. សេចក្តីផ្តើម

ការត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព គឺជាគ្រឹះនៃធនាគារដែលមានសុវត្ថិភាព និងភាពត្រឹមត្រូវ។ ដើម្បីបង្កើតការត្រួតពិនិត្យ ផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ប្រាសាក់ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០១ ដោយមានតួនាទី និងទំនួលខុសត្រូវច្បាស់លាស់សម្រាប់ផ្តល់ការវាយតម្លៃដោយឯករាជ្យ លើភាពគ្រប់គ្រាន់ប្រជ្រោយ ប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអនុវត្តដោយអ្នកគ្រប់គ្រង។ នាយកដ្ឋានសវនកម្មរាយការណ៍ផ្ទាល់ទៅគណៈកម្មាធិការសវនកម្ម ថ្នាក់ក្រុមប្រឹក្សាភិបាល ។

នៅដំណាច់ឆ្នាំ២០២០ នាយកដ្ឋានមានបុគ្គលិកសវនកម្មផ្ទៃក្នុងជំនាញចំនួន ១១០រូប ក្នុងនោះ ៩៥រូប បម្រើការនៅតាមការិយាល័យភូមិភាគ/សាខា។ នាយកដ្ឋាននឹងផ្លាស់ប្តូរទីតាំងការងាររបស់សវនករផ្ទៃក្នុង តាមភូមិភាគគ្រប់ពេល ប្រសិនបើនាយកនាយកដ្ឋាន សវនកម្មផ្ទៃក្នុងបារម្ភអំពីប្រសិទ្ធភាពនៃការងារសវនកម្ម ឬ/ និង ទំនាស់ផលប្រយោជន៍ ។

## ២. វិសាលភាពនៃការធ្វើសវនកម្ម ក្នុងឆ្នាំ២០២០

- ផលប័ត្រកម្ចី (ត្រួតពិនិត្យឯកសារកម្ចី និងជួបសម្ភាសន៍អតិថិជនផ្ទាល់ ដើម្បីបញ្ជាក់ពីសមតុល្យនៅជំពាក់ និងផ្ទៀងផ្ទាត់ថាការផ្តល់កម្ចីអនុលោមតាមគោលនយោបាយឥណទាននិងគោលការណ៍ការពារអតិថិជនសម្រាប់កម្ចីថ្មីនិងកម្ចីចាស់)។
- សាច់ប្រាក់ជាក់ស្តែងនៅតាមសាខា (រាប់សាច់ប្រាក់ជាក់ស្តែងដោយមិនជូនដំណឹងជាមុន និងសង្កេតមើលការបើកទូសុវត្ថិភាព)។
- ប្រតិបត្តិការសាខា (ត្រួតពិនិត្យការគ្រប់គ្រងសាច់ប្រាក់ ការផ្តល់សេវាកម្មអតិថិជន ប្រតិបត្តិការដាក់ និងដកប្រាក់ការគ្រប់គ្រងទ្រព្យសម្បត្តិ ការរក្សាទុកឯកសារ ការគ្រប់គ្រងការិយាល័យ ការគ្រប់គ្រងធនធានមនុស្សកម្រិតសាខា ព័ត៌មានវិទ្យា តាមសាខា ចំណាយទូទៅ ប្រតិបត្តិការផ្ទេរប្រាក់ និងប្រាក់ចំណូលផ្សេងៗ និងការប្រឆាំងការសម្អាតប្រាក់ និងការប្រយុទ្ធ ប្រឆាំងហិរញ្ញប្បទានភេរវកម្ម។
- នាយកដ្ឋាននៅការិយាល័យកណ្តាល (ត្រួតពិនិត្យការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិក ការលាឈប់ និងការបញ្ចប់កិច្ចសន្យាការងារ ការប្រឆាំងការសម្អាតប្រាក់ និងការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម ការត្រួតពិនិត្យផ្ទៃក្នុងលើការរៀបចំ របាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការគ្រប់គ្រងសន្ទនីយភាព)។
- ព័ត៌មានវិទ្យា (ត្រួតពិនិត្យការគ្រប់គ្រងសន្តិសុខប្រព័ន្ធធនាគារអេឡិចត្រូនិក ការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម អភិបាលកិច្ចព័ត៌មានវិទ្យា និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតដែលចាំបាច់)។
- ករណីក្លែងបន្លំ និងការរំលោភបំពានគោលនយោបាយផ្ទៃក្នុង។

## ៣. ស្តង់ដារសម្រាប់ការអនុវត្តវិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង

ការងាររបស់សវនកម្មផ្ទៃក្នុង គឺការគោរពទៅតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា បទបញ្ជាផ្ទៃក្នុងរបស់ប្រាសាក់ និងគោលបំណង និងវិធីសាស្ត្ររបស់ខ្លួន។

សវនកម្មផ្ទៃក្នុងក៏ប្រកាន់ខ្ជាប់នូវផ្នែកខ្លះនៃនិយមន័យនៃការធ្វើសវនកម្មផ្ទៃក្នុង របស់វិទ្យាស្ថានសវនកម្មផ្ទៃក្នុង (IIA) ។ ក្រមសីលធម៌ និង ស្តង់ដារអន្តរជាតិសម្រាប់ការអនុវត្តប្រកបដោយវិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង ("ស្តង់ដារ") ។ លើសពីនេះទៅទៀត សវនកម្មផ្ទៃក្នុង ត្រូវពិចារណាលើការប្រឹក្សា និង ការណែនាំរបស់វិទ្យាស្ថានសវនកម្មផ្ទៃក្នុង (IIA) ដើម្បីដឹកនាំការងាររបស់ខ្លួន។

## ៤. សង្ខេបលទ្ធផលសវនកម្ម

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តសកម្មភាពសវនកម្ម ដោយផ្អែកលើផែនការសវនកម្មប្រចាំឆ្នាំដែលត្រូវបានអនុម័ត ដោយគណៈកម្មាធិការសវនកម្ម និងសម្របទៅនឹងប្រតិបត្តិការអាជីវកម្មជាក់ស្តែង។ គម្រោងសវនកម្មដែលបានគ្រោងទុក និងមិនបានគ្រោងទុកបានបំពេញក្នុងឆ្នាំ២០២០ មានដូចខាងក្រោម៖

| ល.រ | ផ្នែកត្រួតពិនិត្យ | សមិទ្ធិផល | ការវាយតម្លៃប្រព័ន្ធត្រួតពិនិត្យ |
|---|---|---|---|
| ០១ | ត្រួតពិនិត្យកម្ចី (កម្ចីធម្មតា កម្ចីមិនដំណើរការ កម្ចីលុបចេញពីបញ្ជី គ្រប់សាខា) | ៨៥.១៤៨ គណនី (១៦,២៣% នៃចំនួនគណនីសរុប) | ពេញចិត្ត |
| ០២ | ការរាប់សាច់ប្រាក់ | ១.៨០២ ដង | - |
| ០៣ | ប្រតិបត្តិការសាខា (១លើក ក្នុង១សាខា) | ១៨០ សាខា | ពេញចិត្ត |
| ០៤ | ការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិក | ១ ដង | ពេញចិត្ត |
| ០៥ | ការលាឈប់ និងការបញ្ចប់កិច្ចសន្យាការងារ | ១ ដង | ត្រូវការកែលម្អ |
| ០៦ | ការត្រួតពិនិត្យផ្ទៃក្នុងលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ | ១ ដង | ពេញចិត្ត |
| ០៧ | ការគ្រប់គ្រងទ្រព្យសម្បត្តិ | ១ ដង | ពេញចិត្ត |
| ០៨ | ការគ្រប់គ្រងសន្ទនីយភាព | ១ ដង | ពេញចិត្ត |
| ០៩ | ការប្រឆាំងការសម្អាតប្រាក់ និងការប្រយុទ្ធប្រឆាំងហិរញ្ញប្បទានភេរវកម្ម | ១ ដង | ត្រូវការកែលម្អ |
| ១០ | ការគ្រប់គ្រងសន្តិសុខប្រព័ន្ធធនាគារអេឡិចត្រូនិក | ១ ដង | ពេញចិត្ត |
| ១១ | ការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម | ១ ដង | ត្រូវការកែលម្អ |
| ១២ | អភិបាលកិច្ចព័ត៌មានវិទ្យា | ១ ដង | ពេញចិត្ត |
| ១៣ | សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតដែលចាំបាច់ | ១ ដង | ពេញចិត្ត |
| ១៤ | ការស៊ើបអង្កេត ការក្លែងបន្លំ និងករណីមិនប្រក្រតីផ្សេងៗ | ៨៥ ដង | - |
| ១៥ | ត្រួតពិនិត្យអសមតុល្យសាច់ប្រាក់ | ៤៤ ដង | - |

- នាយកដ្ឋានបានចេញរបាយការណ៍សវនកម្មចំនួន ១.៩២៩ ជូនថ្នាក់គ្រប់គ្រងសាខា និងប្រធាននាយកដ្ឋានពាក់ព័ន្ធ។
- នាយកដ្ឋានបានរាយការណ៍ពីលទ្ធផលសវនកម្ម ជូនគណៈកម្មាធិការសវនកម្មរៀងរាល់ត្រីមាស។

## ៥. សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលសវនកម្មក្នុងឆ្នាំ ២០២០ នាយកដ្ឋានសវនកម្មផ្ទៃក្នុងសន្និដ្ឋានថា៖

- ប្រាសាក់បានបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ដើម្បីការពារទ្រព្យសម្បត្តិរបស់ស្ថាប័ន និងប្រាក់បញ្ញើ របស់សាធារណៈជន ធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាបម្រើអតិថិជន ការពារកំហុសឆ្គងនានាដែលអាចកើតឡើង

ដោយចេតនា ឬអចេតនា និងដើម្បីធានាថា បុគ្គលិកអនុវត្តការងារ ដោយគោរពតាមគោលនយោបាយ និងសេចក្តីណែនាំផ្សេងៗ។

- បុគ្គលិកទទួលបន្ទុក ទាំងនៅការិយាល័យកណ្តាល និងសាខា បានអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីកាត់បន្ថយហានិភ័យ ដែលអាចកើតមានក្នុងពេលធ្វើប្រតិបត្តិការប្រចាំថ្ងៃ។
- អ្នកគ្រប់គ្រងទទួលបន្ទុក បានអនុវត្តសកម្មភាពកែតម្រូវ និងសកម្មភាពការការពារយ៉ាងមានប្រសិទ្ធភាព ចំពោះការរកឃើញ និងអនុសាសន៍នានាដែលបានលើកឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

បានអាន និងឯកភាព

កាលបរិច្ឆេទ: ២១ មករា ២០២១

ហត្ថលេខា

**Hana LEE**

ប្រធានគណៈកម្មាធិការសវនកម្ម

កាលបរិច្ឆេទ: ២១ មករា ២០២១

ហត្ថលេខា

**អ៊ុក សារឿង**

ប្រធានសវនករផ្ទៃក្នុង

# ផ្នែកទី ៦ - របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធនៃរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យដូចមានជូនភ្ជាប់។

# ផ្នែកទី ៧ - ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញពីព័ត៌មានប្រតិបត្តិការសំខាន់ៗ ជាមួយភាគីជាប់ពាក់ព័ន្ធនៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយបញ្ជាក់ពីឈ្មោះ ទំនាក់ទំនងរវាងបុគ្គលចុះបញ្ជីលក់មូលបត្រ និងភាគីជាប់ពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងនោះដូចខាងក្រោម៖

## ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

- ប្រាក់កម្ចីពីក្រុមហ៊ុន DEG - DEUTSCHE INVESTITIONS- UND ENTWICKLUNGSGESELLSCHAFT MBH ជាមួយប្រាក់កម្ចីចំនួន ៥ លានដុល្លារអាមេរិក និង ប៊ីអ៊ីអេ (BEA) ដែលជាម្ចាស់ភាគហ៊ុនរបស់ប្រាសាក់ ហើយក៏ជាភាគីមួយ នៃការផ្ដល់ប្រាក់កម្ចីក្នុងកិច្ចសន្យាប្រាក់កម្ចីនេះជាមួយនឹងទឹកប្រាក់កម្ចីចំនួន ១០ លានដុល្លារអាមេរិក។ កិច្ចសន្យាប្រាក់កម្ចីនេះ មានតម្លៃស្មើនឹង ៦០ លានដុល្លារអាមេរិក។
- កិច្ចសន្យាឥណទានបង្វិល ពីធនាគារ ខេប៊ី គូកមីន (KB Kookmin Bank) សាខាហុងកុង ដែលមានទឹកប្រាក់កម្ចីចំនួន ១០០ លានដុល្លារអាមេរិក។
- អនុបំណុលពីធនាគារ ខេប៊ី គូកមីន (KB Kookmin Bank) សាខាហុងកុង ក្នុងទឹកប្រាក់កម្ចីចំនួន ៥០ លានដុល្លារ។
- ប្រាក់កម្ចីពីធនាគារ ខេប៊ី គូកមីន (KB Kookmin Bank) សាខាកម្ពុជា ជាប្រាក់រៀល ដែលមានចំនួនទឹកប្រាក់ ៥ លានដុល្លារអាមេរិក។
- ឥណទានជាក្រុម ដែលទទួលបានពីធនាគារ ខេប៊ី គូកមីន (KB Kookmin Bank) សាខាហុងកុង ជាមួយទំហំទឹកប្រាក់សរុបរហូតដល់ ១៥០ លាន ដុល្លារអាមេរិក។

## ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលជាន់ខ្ពស់

មិនមាន

## គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

មិនមាន

## ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និង ភាគហ៊ុនិក ដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ

មិនមាន

**ខ. ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហូលឌីង របស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះ កើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ**

មិនមាន

**ច. ប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល**

មិនមាន

**ឆ. ប្រតិបត្តិការសំខាន់ៗ ជាមួយអភិបាលដែលកាន់មុខតំណែងណាមួយ នៅក្នុងសមាគម ឬ អង្គភាព មិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ**

មិនមាន

**ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ**

មិនមាន

# ផ្នែកទី ៨ - ការពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមនេះ គឺជាការពិភាក្សារបស់គណៈគ្រប់គ្រងប្រាសាក់ ទៅលើលទ្ធផល ប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលត្រូវបានធ្វើសវនកម្មរួចរាល់ដោយសវនករឯករាជ្យ EY ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRS") និងបទបញ្ញត្តិនានា ដែលចេញដោយធនាគារជាតិនៃកម្ពុជា។ គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគទៅលើសមាសធាតុសំខាន់ៗ នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗ ដែលមានផលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ប្រាសាក់។

## ក. និន្នាការទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ប្រាសាក់ រកប្រាក់ចំណូលបានមកពីប្រភពសំខាន់ៗចំនួន ៣ ដូចខាងក្រោម៖

- **ចំណូលការប្រាក់៖** ប្រាក់កម្ចីផ្តល់ជូនអតិថិជន និងប្រាក់បញ្ញើនៅធនាគារ។
- **ចំណូលកម្រៃជើងសា៖** ចំណូលកម្រៃជើងសាពីឥណទាន កម្រៃពីការបោះផ្សាយប័ណ្ណ និងចំណូលកម្រៃជើងសាពីសេវាកម្មផ្ទេរប្រាក់ក្នុងស្រុក។
- **ចំណូលផ្សេងៗ៖** ការពិន័យលើឥណទាន ការប្រមូលមកវិញពីឥណទានដែលបានលុបចេញពីបញ្ជី ចំណេញពីអត្រាប្តូរប្រាក់ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ឆ្នាំ២០២០ | | ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) | ទឹកប្រាក់សរុប (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ១.៧៥៤.៦៦៦ | ៩៦,១១% | ១.៤៤៣.៥៤៧ | ៩២,២៥% |
| ២ | ចំណូលកម្រៃជើងសា | ២៨.០៤៥ | ១,៥៤% | ៧៣.៩៣៤ | ៤,៧២% |
| ៣ | ចំណូលផ្សេងៗ | ៤២.៨៨៧ | ២,៣៥% | ៤៧.៣៨៤ | ៣,០៣% |
| **ចំណូលសរុប** | | **១.៨២៥.៥៩៨** | **១០០%** | **១.៥៦៤.៨៦៥** | **១០០%** |

ចំណូលការប្រាក់ គឺជាប្រភពដ៏សំខាន់សម្រាប់ ប្រាសាក់ ក្នុងការបង្កើតប្រាក់ចំណូល។ នៅឆ្នាំ ២០២០ ចំណូលការប្រាក់មានប្រមាណ ៩៦,១១% នៃចំណូលសរុប ខណៈដែល ៩៩,៩៥% នៃចំណូលការប្រាក់ គឺបានមកពីប្រាក់កម្ចីផ្តល់ជូនអតិថិជន។ បើប្រៀបធៀបតាមផ្នែកទៅនឹងរយៈពេលដូចគ្នាពីលទ្ធផលកាលពីឆ្នាំមុន ចំណូលកម្រៃជើងសាមានការថយចុះចំនួន ៤៥.៨៨៩ លានរៀល ឬ -៦២,០៧% ដោយមានការអនុវត្តនូវអត្រាការប្រាក់ប្រសិទ្ធិភាពនៅក្នុងឆ្នាំ ២០២០ ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ចំណែកឯចំណូលការប្រាក់បានកើនឡើងចំនួន ៣១១.១១៩ លានរៀល ស្មើនឹង ២១,៥៥% ដោយសារកំណើនដ៏ខ្លាំងខ្លានៃប្រាក់កម្ចីផ្តល់ជូនអតិថិជនក្នុងអំឡុងឆ្នាំ២០២០។

## ៣. ការវិភាគគម្លាតចំណេញដុល

ការវិភាគគម្លាតចំណេញដុល មិនបានបង្ហាញនៅក្នុងទម្រង់នៃរបាយការណ៍លទ្ធផលពេញលេញដែលរៀបចំដោយ ប្រាសាក់ នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ វាបង្ហាញពីចំណូលការប្រាក់សុទ្ធ ដែលបានមកពីចំណូលការប្រាក់ ដកចំណាយការប្រាក់ដែលបានចង្អុលបង្ហាញនៅក្នុងចំណុចទី៤ ស្តីពីការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ។

## ៤. ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ/ខាត មុនបង់ពន្ធ | ឆ្នាំ២០២០ (លានរៀល) | ឆ្នាំ២០១៩ (លានរៀល) | លម្អៀង (លានរៀល) | លម្អៀង (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ១.៧៥៤.៦៦៦ | ១.៤៤៣.៥៤៧ | ៣១១.១១៩ | ២១,៥៥% |
| ចំណាយការប្រាក់ | (៨០៩.០៥៥) | (៦៦៦.៨០៦) | (១៤២.២៤៩) | ២១,៣៣% |
| **ចំណូលពីការប្រាក់សុទ្ធ** | **៩៤៥.៦១១** | **៧៧៦.៧៤១** | **១៦៨.៨៧០** | **២១,៧៤%** |
| ចំណូលកម្រៃជើងសា | ២៨.០៤៥ | ៧៣.៩៣៤ | (៤៥.៨៨៩) | -៦២,០៧% |
| ចំណាយកម្រៃជើងសា | (៦៦៥) | (១៤.០៧០) | ១៣.៤០៥ | -៩៥,២៧% |
| **ចំណូលពីកម្រៃជើងសាសុទ្ធ** | **២៧.៣៨០** | **៥៩.៨៦៤** | **(៣២.៤៨៤)** | **-៥៤,២៦%** |
| ចំណូលផ្សេងៗ | ៣៦.៧២១ | ៤៧.៣៨៤ | (១០.៦៦៣) | -២២,៥០% |
| ចំណូលពីជំនួយ | ៤.០៦៤ | - | ៤.០៦៤ | ១០០% |
| ចំណេញ/(ខាតសុទ្ធ)ពីការប្តូររូបិយប័ណ្ណ | ២.១០២ | (២.០៩២) | ៤.១៩៤ | -២០០,៤៨% |
| **ចំណូលផ្សេងៗសរុប** | **៤២.៨៨៧** | **៤៥.២៩២** | **(២.៤០៥)** | **-៥,៣១%** |
| **ចំណូលសរុបពីការប្រាក់ កម្រៃជើងសា និងចំណូលផ្សេងៗ** | **១.០១៥.៨៧៨** | **៨៨១.៨៩៧** | **១៣៣.៩៨១** | **១៥,១៩%** |
| ចំណាយលើបុគ្គលិក | (២៧៦.៧១២) | (២៤៣.៥០៤) | (៣៣.២០៨) | ១៣,៦៤% |
| សំវិធានធនលើការខាតបង់រំពឹងទុក | (៩៥.៦២០) | (៣៧.៦៧៦) | (៥៧.៩៤៤) | ១៥៣,៨០% |
| ចំណាយទូទៅ និងរដ្ឋបាល | (៦៥.១៧៨) | (៥១.៣៧៤) | (១៣.៨០៦) | ២៦,៨៧% |
| ចំណាយរំលស់ | (២៦.៧៩១) | (២៤.៨២២) | (១.៩៦៩) | ៧,៩៣% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៥៥១.៥៧៥** | **៥២៤.៥២១** | **២៧.០៥៤** | **៥,១៦%** |

នៅឆ្នាំ២០២០ ប្រាក់ចំណេញមុនបង់ពន្ធ បានកើនឡើងចំនួន ២៧.០៥៤ លានរៀល ស្មើនឹង ៥,១៦% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៩ ។ ទោះបីជាចំណូលកម្រៃជើងសា មានការថយចុះគួរឱ្យកត់សម្គាល់សម្រាប់ឆ្នាំនេះ ប៉ុន្តែចំណូលការប្រាក់មានចំនួនខ្ពស់ជាងរយៈពេលមុនប្រហែល ៣១១.១១៩ លានរៀល ស្មើនឹង ២១,៥៥% ដែលជាមូលហេតុចំបងនៃការកើនឡើងនៃប្រាក់ចំណេញមុនបង់ពន្ធ។ ចំណាយក្នុងឆ្នាំក៏មានការកើនឡើងផងដែរ រួមបញ្ចូលទាំងចំណាយលើបុគ្គលិកចំនួន ៣៣.២០៨ លានរៀល ឬ ១៣,៦៤% សំវិធានធនលើការខាតបង់រំពឹងទុកចំនួន ៥៧.៩៤៤ លានរៀល ឬ ១៥៣,៨០% និងចំណាយទូទៅនិងរដ្ឋបាលចំនួន ១៣.៨០៦ លានរៀល ឬ ២៦,៨៧% បើប្រៀបធៀបនឹងឆ្នាំ ២០១៩។ មូលហេតុនៃការកើនឡើងនៃ

ចំណាយ គឺដោយសារមានការកើនឡើងនៃចំនួនបុគ្គលិក និងផលិតភាពការងារ ការកើនឡើងនៃឥណទាន និងឥណទានមិនដំណើរការ ការពង្រីកប្រតិបត្តិការ និងការការពារសុខភាព និងសុវត្ថិភាពពីការរីករាលដាលនៃជំងឺ កូវីដ-១៩ ។

## ៥. ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ឆ្នាំ២០២០ (លានរៀល) | ឆ្នាំ២០១៩ (លានរៀល) | លម្អៀង (លានរៀល) | លម្អៀង (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៥៥១.៥៧៥ | ៥២៤.៥២១ | ២៧.០៥៤ | ៥,១៦% |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១០៨.០៥៨) | (១០៥.១១៧) | (២.៩៤១) | ២,៨០% |
| **ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | **៤៤៣.៥១៧** | **៤១៩.៤០៤** | **២៤.១១៣** | **៥,៧៥%** |

នៅក្នុងឆ្នាំ ២០២០ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធបានកើនឡើងចំនួន ២៤.១១៣ លានរៀល ដែលស្មើនឹង ៥,៧៥% ដែលនាំឱ្យការចំណាយពន្ធលើប្រាក់ចំណេញ ក៏មានការកើនឡើងផងដែរ។ ដោយសារលទ្ធផលនៃប្រាក់ចំណេញសុទ្ធនៅក្នុងឆ្នាំ២០២០ ប្រាសាក់បានទទួលនូវលទ្ធផលដ៏ល្អ ចំពោះអនុបាតចំណេញធៀបនឹងទ្រព្យសកម្មជាមធ្យម ៣,២៥% និងអនុបាតចំណេញធៀបនឹងមូលធនជាមធ្យម ២៣,៥៣% សម្រាប់រយៈពេល ១២ខែ នៃប្រាក់ចំណេញសុទ្ធចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ឆ្នាំ២០២០ (លានរៀល) | ឆ្នាំ២០១៩ (លានរៀល) | លម្អៀង (លានរៀល) | លម្អៀង (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | ៤៤៣.៥១៧ | ៤១៩.៤០៤ | ២៤.១១៣ | ៥,៧៥% |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | (១៥.៧៨៣) | ១៩.៨២៨ | (៣៥.៦១១) | -១៧៩,៦០% |
| **លទ្ធផលពេញលេញសរុប** | **៤២៧.៧៣៤** | **៤៣៩.២៣២** | **(១១.៤៩៨)** | **-២,៦២%** |

ធាតុនៃលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលតែភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ដែលបានមកពីទ្រព្យសកម្ម និងបំណុល ត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់ចុងគ្រានាការិយបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ចំណែកឯចំណូល និងចំណាយ ដែលបានបង្ហាញក្នុងរបាយការណ៍លទ្ធផលពេញលេញ និងលំហូរសាច់ប្រាក់ ត្រូវបានប្រែសម្រួលដោយប្រើ អត្រាមធ្យមក្នុងការិយបរិច្ឆេទ ខណៈពេលដែលដើមទុនត្រូវបានប្រែសម្រួលតាមអត្រាប្រវត្តិ។

## ៧. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

នៅក្នុងឆ្នាំ ២០២០ កត្តា និងបញ្ហាប្រឈមដែលជះឥទ្ធិពលយ៉ាងខ្លាំង ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ គឺបណ្តាលមកពីការផ្ទុះឡើងនៃជំងឺរាតត្បាត កូវីដ-១៩ ដែលជះឥទ្ធិពលអវិជ្ជមាន ដល់សកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដូចជាការផ្អាក ឬបិទប្រតិបត្តិការអាជីវកម្ម កម្មករបាត់បង់ការងារ ការកើនឡើងនៃឥណទានមិនដំណើរការ ប្រាក់ចំណូល និងសន្សំមានចំនួនតិច។ ទោះយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំប្រឹងប្រែង និងមានយុទ្ធសាស្ត្រដ៏ល្អក្នុងការបញ្ឈប់ និងកាត់បន្ថយនៃការចម្លងជំងឺ កូវីដ-១៩ ដោយរួមទាំងការរកឃើញករណីចម្លង ជាមួយនឹងការឆ្លើយតបយ៉ាងឆាប់រហ័ស ការរក្សាគម្លាតសង្គម ការតាមដាននៃអ្នកជាប់ពាក់ព័ន្ធ និងការធ្វើចត្តាឡីស័ក។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ប្រាសាក់ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេនៅក្នុងប្រទេសកម្ពុជា ដោយផ្តល់ជូននូវផលិតផល និងសេវាប្រកបដោយភាពច្នៃប្រឌិត និងការធ្វើពិពិធកម្មតាមរយៈបណ្តាញចែកចាយទំនើប។ ដោយសារតែជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ ប្រាសាក់ ធ្វើការផ្តោតសំខាន់ទៅលើសហគ្រាសធុនតូចបំផុត ធុនតូច និងធុនមធ្យម និងការស្វែងរកឱកាសដើម្បីពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួនតាមរយៈការទាញយកអត្ថប្រយោជន៍ពីគម្លាតនៃការផ្គត់ផ្គង់សេវាធនាគារនៅក្នុងប្រទេសកម្ពុជា។ ប្រាសាក់ ក៏បានកំណត់ឱកាសដើម្បីបង្កើនចំណេញភាពដល់អតិថិជនដែលមានស្រាប់ និងទាក់ទាញអតិថិជនថ្មី ដោយផ្តល់ជូននូវផលិតផល និងសេវាបន្ថែម ព្រមទាំងភាពច្នៃប្រឌិតថ្មីៗ។

ប្រាសាក់ បន្តធ្វើបច្ចុប្បន្នភាព និងពង្រីកផលិតផល និងសេវាកម្មរបស់ខ្លួនដើម្បីបំពេញតម្រូវការរបស់អតិថិជន។ ប្រាសាក់ បានវិនិយោគយ៉ាងច្រើនទៅលើបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការធ្វើឌីជីថលផ្នែកសេវាកម្មដើម្បីបង្កើនភាពងាយស្រួល និង អនុញ្ញាតឱ្យអតិថិជនអាចប្រើប្រាស់ប្រព័ន្ធធនាគារដោយខ្លួនឯងបាននៅគ្រប់ទីកន្លែង។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ប្រាសាក់ កំពុងធ្វើប្រតិបត្តិការក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់នូវផលិតផល និងសេវាហិរញ្ញវត្ថុដល់អតិថិជន ដូច្នេះ ការវិភាគទៅលើការប្រែប្រួលនៃតម្លៃវត្ថុធាតុដើម មិនត្រូវបានអនុវត្តចំពោះក្រុមហ៊ុនឡើយ។

### ៣. ការវិភាគទៅលើពន្ធ

ប្រាសាក់ មានកាតព្វកិច្ចបង់ពន្ធ និងអាករនានាជូនរដ្ឋស្ថិតនៅក្រោមច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រាសាក់ គឺជាអ្នកជាប់ពន្ធធំ និងតម្រូវឱ្យបង់ពន្ធតាមរបបពិតដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ចំណាយពន្ធរួមមានពន្ធដែលបង់ក្នុងឆ្នាំសារពើពន្ធ និងពន្ធពន្យារ។ ចំណាយពន្ធត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

សម្រាប់ការអនុលោមភាពល្អលើកាតព្វកិច្ចពន្ធដារ ប្រាសាក់ ទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "មាស" ពីអគ្គនាយកដ្ឋានពន្ធដារនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ ដែលមានសុពលភាព ២ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២០ និងឆ្នាំ២០២១ ។

### ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ គណៈគ្រប់គ្រងមិនបានដឹងពីធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមានភាពមិនប្រក្រតីបានកើតឡើងដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ជាមួយនឹងស្ថានភាពបច្ចុប្បន្ននៃការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ គណៈគ្រប់គ្រងនឹងបន្តយកចិត្តទុកដាក់ជានិច្ចចំពោះការវិវឌ្ឍនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងប្រទេសកម្ពុជា និងផលប៉ះពាល់ចំពោះ ប្រតិបត្តិការរបស់ក្រុមហ៊ុន។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នៅឆ្នាំ២០២០ ប្រាសាក់ រកបានចំណូលសរុបប្រមាណ ១.៨២៥.៥៩៨ លានរៀល កើនឡើង ១៦,៦៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩។ ចំណូលការប្រាក់សុទ្ធបានកើនឡើងពី ៧៧៦.៧៤១ លានរៀល ដល់ ៩៤៥.៦១១ លានរៀល ខណៈពេលដែលសម្ពៀតឥណទានសរុបកើនឡើង ២០,៦៨%។ ទោះបីជាសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានទទួលរងផលប៉ះពាល់ ដោយការរីករាលដាលនៃជំងឺកូវីដ-១៩ពេញមួយឆ្នាំក៏ដោយ ប្រាសាក់ នៅតែអាចគ្រប់គ្រង និងធ្វើប្រតិបត្តិការដោយទទួលបានប្រាក់ចំណេញល្អប្រសើរ។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ១. ហានិភ័យនៃអត្រាប្តូរប្រាក់

ហានិភ័យនៃអត្រាប្តូរប្រាក់ ជាហានិភ័យរូបិយប័ណ្ណបរទេសពាក់ព័ន្ធនឹងការខាតបង់ ដែលអាចកើតឡើងដោយសារតែការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណ។ សកម្មភាពអាជីវកម្មរបស់ប្រាសាក់ ឆ្លងកាត់រូបិយប័ណ្ណសំខាន់ៗចំនួន ៣ គឺប្រាក់រៀល ដុល្លារអាមេរិក និងប្រាក់បាតថៃ។ ភាពប្រែប្រួលនៃអត្រាប្តូរប្រាក់អាចជះឥទ្ធិពលខ្លាំងដល់ចំណូលប្រតិបត្តិការ និងប្រាក់ចំណេញរបស់ប្រាសាក់។ អត្រាប្តូរប្រាក់ត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ដោយនាយកដ្ឋានហិរញ្ញកិច្ច។ គោលនយោបាយរបស់ប្រាសាក់ចែងថា ប្រាសាក់នឹងមិនចូលរួមក្នុងសកម្មភាព ដើម្បីទទួលបានប្រាក់ចំណូលពីការធ្វើការជួញដូរកម្មសិទ្ធិ ឬ ការឆក់ឱកាសកេងចំណេញលើការប្រែប្រួលអត្រាប្តូរប្រាក់ អត្រាការប្រាក់ ឬ តម្លៃមូលបត្រឡើយ។ ប្រាសាក់មិនត្រូវបានអនុញ្ញាតឱ្យជួញដូរនៅក្នុងឧបករណ៍រូបិយប័ណ្ណបរទេសរយៈពេលខ្លីឡើយ។ ប្រតិបត្តិការ រូបិយប័ណ្ណបរទេស ឬ ស្ថានភាពរូបិយប័ណ្ណចំហរណាមួយត្រូវបង្ហាញទំនាក់ទំនងច្បាស់លាស់ដល់អាជីវកម្មដែលពាក់ព័ន្ធនឹងអតិថិជន។

*__កម្រិតកំណត់__*

| ការវាស់វែងហានិភ័យ | កម្រិត |
|---|---|
| ស្ថានភាពរូបិយប័ណ្ណបរទេសសរុបធៀបទៅនឹងមូលធនសរុបតាមបទប្បញ្ញត្តិ | ≥ -២០ និង ≤ ២០% |
| ស្ថានភាពរូបិយប័ណ្ណបរទេសតែមួយធៀបទៅនឹងមូលធនសរុបតាមបទប្បញ្ញត្តិ | ≥ -២០ និង ≤ ២០% |

គណៈកម្មាធិការទ្រព្យសកម្ម និងបំណុល ទទួលខុសត្រូវក្នុងការចាត់វិធានការសមស្របដើម្បីការពារហានិភ័យរូបិយប័ណ្ណបរទេសក្នុងកម្រិតទាំងនេះគ្រប់ពេលទាំងអស់។

*__ចំណាត់ការលើ Forex__*

គណៈកម្មាធិការទ្រព្យសកម្ម និងបំណុល នឹងតាមដានការអនុវត្តក្នុងពេលបច្ចុប្បន្ន និងការព្យាករណ៍ចំពោះកម្រិតខាងលើ ហើយនឹងកំណត់វិធានការសមតុល្យដែលសមស្របណាមួយ ក្នុងករណីស្ថានភាពជាក់ស្តែងអាចនឹងឈានដល់ការរំលោភបំពាន។ ឧបករណ៍គ្រប់គ្រងហានិភ័យរូបិយប័ណ្ណបរទេស ដែលអាចទទួលយកបានអាចជួយកាត់បន្ថយស្ថានភាពប្តូររូបិយប័ណ្ណបរទេសវែងសុទ្ធ ឬ ខ្លីសុទ្ធ (net long or short foreign exchange position) ទៅតាមរូបិយប័ណ្ណជាក់លាក់រួមមាន៖

- ការបង្កើតការទូទាត់បន្ថែមលើទ្រព្យសកម្ម Forex (ក្នុងករណីស្ថានភាពខ្លី "short position") ឬបំណុល Forex (ក្នុងករណីស្ថានភាពវែង "long position")។

- ការកាត់បន្ថយ (ការលក់) ទ្រព្យសកម្ម Forex ឬ ការទិញ ត្រលប់មកវិញនូវបំណុលនៅក្នុងទីផ្សារសាច់ប្រាក់សម្រាប់តម្លៃភ្លាមៗ។
- ការប្រើប្រតិបត្តិការនាពេលអនាគតដើម្បីទូទាត់ទ្រព្យសកម្ម Forex ឬ បំណុល Forex បើមិនដូច្នេះទេនឹងបង្កើតស្ថានភាពចំហសុទ្ធខ្លី ឬ ចំហសុទ្ធវែងហួសកម្រិត (excessive short or long net open position)។
- ការបំលែងបំណុល Forex ទៅជាស្ថានភាពរូបិយប័ណ្ណមុខងារដែលមានប្រសិទ្ធភាពដោយប្រើការប្តូររូបិយប័ណ្ណ (cross currency swaps)។

ការគណនាស្ថានភាពចំហសុទ្ធលម្អិតត្រូវបានផ្តល់ជូនក្នុងតារាងខាងក្រោម៖

| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (លានរៀល ឬជាភាគរយ) | ដុល្លារអាមេរិក | ខ្មែររៀល | ថៃបាត | សរុប |
|---|---|---|---|---|
| ទ្រព្យសកម្ម | ១២.៧២២.៧៤៦ | ១.៧៩៨.៤៣៦ | ១០៦.៨៥៩ | ១៤.៦២៨.០៤១ |
| បំណុល និងមូលធន | ១២.៩១៧.០៧០ | ១.៥៣៦.៦២៥ | ១៧៤.៣៤៦ | ១៤.៦២៨.០៤១ |
| ទ្រព្យសកម្មនៅក្រៅខ្លង់តារាងតុល្យការ | ៤០៤.៧០២ | ៤០០ | - | ៤០៥.១០២ |
| បំណុលនៅក្រៅខ្លង់តារាងតុល្យការ | ៤០៤.៧០២ | ៤០០ | - | ៤០៥.១០២ |
| **(+) វែង (ទ្រព្យធំជាងបំណុល) ឬ (-) ខ្លី (បំណុលធំជាងទ្រព្យ)** | **(១៩៤.៣២៤)** | **២៦១.៨១១** | **(៦៧.៤៨៧)** | - |
| **ស្ថានភាព /ទ្រពសកម្មសុទ្ធ** | **-៨,៤៦%** | **១១,៤០%** | **-២,៩៤%** | - |
| កម្រិតកំណត់ % | ២០% | ២០% | ២០% | - |
| **ភាពលើស** | **គ្មាន** | **គ្មាន** | **គ្មាន** | - |

## ២. ហានិភ័យនៃអត្រាការប្រាក់

ហានិភ័យនៃអត្រាការប្រាក់ ត្រូវបានគេឱ្យនិយមន័យជាទូទៅថាជាលទ្ធភាពនៃការផ្លាស់ប្តូរកម្រិតអត្រាការប្រាក់លើទីផ្សារដែលនាំឱ្យផ្ទុះឥទ្ធិពលអវិជ្ជមានទៅលើប្រាក់ចំណូល និងតម្លៃទ្រព្យសកម្មនិងបំណុលរបស់ប្រាសាក់ដែលមានផលប៉ះពាល់ទៅលើមូលធនរបស់ប្រាសាក់។ ការផ្លាស់ប្តូរអត្រាការប្រាក់មានផលប៉ះពាល់ដល់ចំណូលការប្រាក់សុទ្ធរបស់ប្រាសាក់ នៅពេលមានអតុល្យភាពរវាងទ្រព្យសកម្ម និងបំណុលទៅលើការប្រាក់ដែលអាចអនុវត្តបាន។ ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ណាមួយក្នុងអត្រាការប្រាក់អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់លទ្ធផលហិរញ្ញវត្ថុ និងប្រាក់ចំណេញរបស់ប្រាសាក់។ ការវិភាគអំពីហានិភ័យអត្រាការប្រាក់ពាក់ព័ន្ធនឹងទ្រព្យសកម្ម និងបំណុលរបស់ប្រាសាក់ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (លានរៀល) | រហូតដល់ ១ ខែ | ១-៣ ខែ | ៣-១២ ខែ | ១-៥ ឆ្នាំ | លើសពី ៥ ឆ្នាំ | ការប្រែប្រួលមិនពាក់ព័ន្ធនឹងការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ៦៤៩.៥៣៨ | ៦៤៩.៥៣៨ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៦៦៦.៧៥០ | ១.៥១៤ | - | ៦០២ | - | ៣៥២.៩៨៨ | ១.០២១.៨៥៤ |
| សមតុល្យនៅធនាគារផ្សេងៗ | ៧៧២ | - | - | - | - | ១៥.៣០៧ | ១៦.០៧៩ |
| ឥណទានផ្តល់ដល់អតិថិជន | ៣៥៥.១០១ | ៥១១.៧៤៨ | ២.១៥៨.៨៤៤ | ៧.៧០៦.៨៦៧ | ១.៣១៥.៧៩៦ | - | ១២.០៤៨.៣៥៦ |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | - | - | ២.៣២១ | ២.៣២១ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **១.០២២.៦២៣** | **៥១៣.២៦២** | **២.១៥៨.៨៤៤** | **៧.៧០៧.៤៦៩** | **១.៣១៥.៧៩៦** | **១.០២០.១៥៤** | **១៣.៧៣៩.១៤៨** |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងៗ | ១១.៨៧៣ | ៤៤.៥៣៥ | ៨៩.៧៩៩ | - | - | - | ១៤៦.២០៧ |
| ប្រាក់បញ្ញើពីអតិថិជន | ១.៤១៩.១១៩ | ១.៤៧៧.៨៩៤ | ៥.០២៥.២៨១ | ២៦៩.៧១៨ | - | - | ៨.១៩២.០១២ |
| ប្រាក់កម្ចី | ៨៣.១៤៩ | ១១២.៤០០ | ៩៨៦.៩៨២ | ២.០០៦.៤៤១ | ៤.០៤៤ | - | ៣.១៩៣.០១៦ |
| អនុបំណុល | ៤.០៤៧ | ៦.៧៤៥ | ៣៥.០៦១ | ២៥១.៨៤៩ | ១៥៧.១៦២ | - | ៤៥៤.៨៦៤ |
| មូលបត្របំណុលត្រូវសង | - | - | - | ១២២.៣៦៨ | - | - | ១២២.៣៦៨ |
| បំណុលផ្សេងៗ | - | - | - | - | - | ២៥៣.១១៩ | ២៥៣.១១៩ |
| **បំណុលហិរញ្ញវត្ថុសរុប** | **១.៥១៨.១៨៨** | **១.៦៤១.៥៧៤** | **៦.១៣៧.១២៣** | **២.៦៥០.៣៧៦** | **១៦១.២០៦** | **២៥៣.១១៩** | **១២.៣៦១.៥៨៦** |
| **គម្លាតកាលកំណត់** | **(៤៩៥.៥៦៥)** | **(១.១២៨.៣១២)** | **(៣.៩៧៨.២៧៩)** | **៥.០៥៧.០៩៣** | **១.១៥៤.៥៩០** | **៧៦៧.០៣៥** | **១.៣៧៧.៥៦២** |

## វិធានការកាត់បន្ថយហានិភ័យ

*ការគ្រប់គ្រងគម្លាតនៃតម្លៃដែលអាចប្រែប្រួល*

គម្លាតអត្រាការប្រាក់គឺជាទម្រង់ទូទៅនៃការវាស់ស្ទង់ភាពប្រែប្រួលអត្រាការប្រាក់។ គម្លាតនៃការវាយតម្លៃឡើងវិញ គឺស្មើនឹងអត្រាទ្រព្យសកម្មដែលងាយប្រែប្រួល (Rate Sensitive Assets) ដកនឹងអត្រាបំណុលដែលងាយប្រែប្រួល (Rate Sensitive Liabilities) ។

ប្រាសាក់ ព្យាយាមធ្វើឱ្យមានតុល្យភាពរវាងការកាត់បន្ថយហានិភ័យចំពោះប្រាក់ចំណូល ពីការផ្លាស់ប្តូរអវិជ្ជមានក្នុងអត្រាការប្រាក់ និងបង្កើនប្រាក់ចំណូលការប្រាក់សុទ្ធតាមរយៈការរំពឹងទុកត្រឹមត្រូវនៃទិសដៅ និងទំហំនៃការផ្លាស់ប្តូរអត្រាការប្រាក់។ ការខិតទៅជិតគម្លាតវិជ្ជមាន ប្រាសាក់ នឹងទទួលបានអត្ថប្រយោជន៍ ប្រសិនបើអត្រាការប្រាក់កើនឡើង ហើយការខិតទៅជិតគម្លាតអវិជ្ជមាន ប្រាសាក់ នឹងទទួលបានអត្ថប្រយោជន៍ ប្រសិនបើអត្រាការប្រាក់ធ្លាក់ចុះ។ ដែនកំណត់អត្រាការប្រាក់របស់ប្រាសាក់ត្រូវបានអនុវត្ត និងត្រួតពិនិត្យឡើងវិញជារៀងរាល់ខែ។ របាយការណ៍គម្លាតត្រូវបានយកមកអនុវត្ត ដើម្បីវាស់ទំហំហានិភ័យចំណូលការប្រាក់ ដែលកើតឡើងពីចលនាអត្រាការប្រាក់។ ប្រាសាក់ ផ្តោតសំខាន់ទៅលើគម្លាតសុទ្ធនៅក្នុងរយៈពេលកំណត់ ៣០ ៩០ ១៨០ ២៧០ និង៣៦៥ ថ្ងៃ។

ប្រាសាក់ ពិចារណាអំពីដែនកំណត់នៃការវិភាគគម្លាតនៃការវាយតម្លៃដូចខាងក្រោម៖

- អត្រាការប្រាក់លើទ្រព្យសកម្ម និងអត្រាការប្រាក់លើបំណុល មិនតែងតែផ្លាស់ប្តូរតាមទំហំ ឬ ល្បឿនដូចគ្នាឡើយ
- លក្ខណៈជាជម្រើសនៃឧបករណ៍ដាក់ប្រាក់បញ្ញើ និងប្រាក់កម្ចីជាច្រើនមិនអាចកំណត់បានភ្លាមៗឡើយ
- ហានិភ័យដែលកើតចេញពីអាជីវកម្មថ្មីជាទូទៅមិនត្រូវបានកត់ត្រាឡើយ
- ការវិនិយោគ/មូលនិធិដែលមានការវាយតម្លៃអាចនឹងធ្លាក់ចុះក្នុងអត្រាខុសគ្នាខ្លាំងពីអត្រាបច្ចុប្បន្ន។

ដើម្បីដោះស្រាយដែនកំណត់នៃការវិភាគតាមវិធីសាស្ត្រចាស់ពីគម្លាតនៃតម្លៃដែលអាចប្រែប្រួល ប្រាសាក់ បានបន្ថែមឧបករណ៍វិភាគ និងវិធីសាស្ត្រសាកល្បងលើការប្រែប្រួលអត្រាការប្រាក់ (ដូចមាននៅខាងក្រោម)។

*វិធីសាស្ត្រសាកល្បងលើចំណូលការប្រាក់សុទ្ធ*

វិធីសាស្ត្រសាកល្បងនេះ គឺផ្តោតលើការវាស់វែងហានិភ័យចំពោះប្រាក់ចំណូលសុទ្ធ ដោយការព្យាករណ៍លក្ខខណ្ឌអត្រាកាប្រាក់ខុសគ្នា។ គំរូនៃការរៀបចំវិធីសាស្ត្រសាកល្បង រួមបញ្ចូល ធ្វើការវិភាគ «ប្រសិនបើ» ("what if") ដើម្បីកំណត់លទ្ធផលយុទ្ធសាស្ត្រផ្សេងៗគ្នាលើទម្រង់ហានិភ័យ និងផលចំណេញរបស់ប្រាសាក់។

តាមរយៈការប្រើប្រាស់វិធីសាស្ត្រសាកល្បងនេះ ប្រាសាក់ ពិចារណាលើការសន្មត់ជាក់ស្តែងអំពីល្បឿន និងទំហំនៃអត្រាផលិតផលឥណទាន និងប្រាក់បញ្ញើដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរទីផ្សារជារូបិយប័ណ្ណផ្សេងៗ។ ផលប៉ះពាល់នៃអត្រាបង់ប្រាក់ជាមុនលើឥណទានត្រូវបានយកមកពិចារណាផងដែរ។ គណៈគ្រប់គ្រងធ្វើការវាយតម្លៃ និងរៀបចំឯកសារដោយប្រុងប្រយ័ត្នដើម្បីធ្វើការសន្មត់ផ្អែកលើវិធីសាស្ត្រសាកល្បងនេះ។ ផលប៉ះពាល់ជុំទីពីរអំពីការផ្លាស់ប្តូរតម្រូវការឥណទាន និងការផ្គត់ផ្គង់ប្រាក់បញ្ញើបន្ទាប់ពីការកែតម្រូវអត្រាដែលបានសន្មត់មិនមែនជាផ្នែកនៃវិធីសាស្ត្រតេស្តសាកល្បងនេះឡើយ។

ខណៈពេលដែលវិធីសាស្ត្រសាកល្បង អាចវាយតម្លៃហានិភ័យអត្រាការប្រាក់សម្រាប់រយៈពេលខ្លី (១ឆ្នាំ) ប្រាសាក់ មិនពឹងផ្អែកលើការវិភាគនេះដើម្បីកត់ត្រា និងបែងចែកហានិភ័យពាក់ព័ន្ធនឹងអតុល្យភាពនៃការវាយតម្លៃរយៈពេលវែងឡើយ។

ការវិភាគគម្លាតតាមរយៈការថ្លឹងថ្លែងរយៈពេល (Duration-weighted) នៃតារាងតុល្យការត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃស្ថានភាពអត្រាថេរក្នុងរយៈពេលវែង។

*<u>គម្លាតនៃតម្លៃដែលអាចប្រែប្រួលតាមរយៈវិធីសាស្ត្រការថ្លឹងរយៈពេល (Duration-Weighted Re-pricing Gap)</u>*

បន្ថែមលើភាពងាយនឹងប្រែប្រួលប្រាក់ចំណូលចរន្ត របាយការណ៍គម្លាតនៃតម្លៃអត្រាការប្រាក់ដែលអាចប្រែប្រួល អាចត្រូវបានប្រើប្រាស់ដើម្បីផ្តល់នូវការប៉ាន់ស្មានអំពីផលប៉ះពាល់តម្លៃលើទ្រព្យសកម្ម និងបំណុលបន្ទាប់ពីការផ្លាស់ប្តូរអត្រាការប្រាក់លើទីផ្សារ។ តាមរយៈការវាយតម្លៃការផ្លាស់ប្តូរតម្លៃទ្រព្យសកម្ម និងបំណុល បន្ទាប់ពីការវាយតម្លៃអត្រានេះ ប្រាសាក់ អាចកំណត់ពីការខាតបង់ផ្នែកសេដ្ឋកិច្ច ឬ ចំណេញមូលធននៅកម្រិតនៃការធ្វើវិធីសាស្ត្រសាកល្បងជាក់ផ្សេងៗគ្នា។

ប្រាសាក់ គណនាម៉ាទ្រីស (matrix) នៃការប៉ាន់ស្មានរយៈពេលច្បាស់លាស់ជាងមុនសម្រាប់ផ្នែកនីមួយៗ នៅក្នុងរបាយការណ៍គម្លាតនៃការវាយតម្លៃ ពោលគឺចំណុចប្រសព្វរវាងចន្លោះពេល និងធាតុនៅក្នុងតារាងតុល្យការ។ សម្រាប់គោលបំណងនេះ ប្រាសាក់ រក្សាបានពេលវេលាគ្រប់គ្រាន់សម្រាប់ការវាយតម្លៃ។ គម្លាតឆ្ងាយពីគ្នាទាំងនេះ កាន់តែមានសារៈសំខាន់ សម្រាប់ផលប៉ះពាល់សេដ្ឋកិច្ចរយៈពេលវែង។ ការវិភាគរយៈពេលត្រូវការចំណេះដឹងអំពីអត្រាកិច្ចសន្យាជាមធ្យម ដែលអាចអនុវត្តបានចំពោះធាតុនីមួយៗ និងទិន្នផលអប្បហារទីផ្សារថ្មីបន្ទាប់ពីការផ្លាស់ប្តូរអត្រា។ ជាមួយនឹងការសន្មត់ទាំងនេះប្រាសាក់អាចគណនាម៉ាទ្រីសនៃ duration-weights ដែលត្រូវបានកែតម្រូវដើម្បីធ្វើការអនុវត្តទៅលើធាតុនៅក្នុងរបាយការណ៍គម្លាតនៃការវាយតម្លៃស្របគ្នា។

ចក្ខុវិស័យមូលធនសេដ្ឋកិច្ចតាមរយៈវិធីសាស្ត្រគម្លាតតាមរយៈការថ្លឹងថ្លែងរយៈពេល (duration-weighted) សង្កត់ធ្ងន់លើផលប៉ះពាល់តម្លៃនៃតារាងតុល្យការរយៈពេលវែងនៃការផ្លាស់ប្តូរអត្រាការប្រាក់។ នេះគឺជាការបំពេញបន្ថែមដ៏សំខាន់មួយចំពោះវិធីសាស្ត្រ រកប្រាក់ចំណូលក្នុងរយៈពេលខ្លីយ៉ាងតឹងរឹង ដែលផ្អែកលើវិធីសាស្ត្រតេស្ត សាកល្បងជាក់ស្តែងប្រាក់នៃចំណូលការប្រាក់សុទ្ធ។

*<u>កម្រិតហានិភ័យអត្រាការប្រាក់</u>*

កម្រិតហានិភ័យអត្រាការប្រាក់មានដូចខាងក្រោម៖

| ការវាស់វែងហានិភ័យអត្រាការប្រាក់ | និយមន័យ | ដែនកំណត់ |
|---|---|---|
| ចំណូលការប្រាក់សុទ្ធដែលមានហានិភ័យ **គម្លាតនៃតម្លៃដែលអាចប្រែប្រួល** | ការប្រើការវិភាគគម្លាតនៃតម្លៃដែលអាចប្រែប្រួល លក្ខខណ្ឌអត្រាទីផ្សារនេះ៖<br>ចំណុចមូលដ្ឋាន +២០០/-១០០ ក្នុងអត្រា swap ទៅជាដុល្លារអាមេរិកក្នុងរយៈពេល ៤ ឆ្នាំ។<br>ចំណុចមូលដ្ឋាន +២០០/២០០ ក្នុងធនាគារ ឈានមុខគេចំនួន ១០ នៅអត្រាប្រាក់បញ្ញើក្នុង រយៈពេល ១ ឆ្នាំ និង<br>ចំណុចមូលដ្ឋាន +២០០/-២០០ អត្រា BIBOR អត្រាប្រាក់បាតថៃ ក្នុងរយៈពេល ៣ ខែ។<br>អាចដាច់ដោយឡែក និងរួមបញ្ចូលគ្នា ដែលមិនឈានដល់ការធ្លាក់ចុះនៃចំណូលការប្រាក់សុទ្ធច្រើនជាង ២៥% បើប្រៀបធៀបទៅនឹងចំណូល | ≤ ២៥% នៃចំណូលការប្រាក់សុទ្ធជាក់ស្តែងនាពេលថ្មីៗ |

| ការវាស់វែងហានិភ័យអត្រាការប្រាក់ | និយមន័យ | ដែនកំណត់ |
|---|---|---|
| | ការប្រាក់សុទ្ធជាក់ស្តែង ១២ ខែមុន។ | |
| ចំណូលការប្រាក់សុទ្ធដែលមានហានិភ័យ **គម្លាតនៃតម្លៃដែលអាចប្រែប្រួល** | ដោយប្រើប្រាស់វិធីសាស្រ្តសាកល្បងលក្ខខណ្ឌអត្រាទីផ្សារនេះ៖ ចំណុចមូលដ្ឋាន +២០០/-១០០ ក្នុងអត្រា swap ទៅជាដុល្លារអាមេរិក ក្នុងរយៈពេល ៤ ឆ្នាំ។ ចំណុចមូលដ្ឋាន +២០០/-២០០ ក្នុងធនាគារ ឈានមុខគេចំនួន ១០ នៅអត្រាប្រាក់បញ្ញើក្នុងរយៈពេល ១ ឆ្នាំ និង ចំណុចមូលដ្ឋាន +២០០/-២០០ ក្នុងអត្រា BIBOR អត្រាប្រាក់បាតថៃ ក្នុងរយៈពេល ៣ ខែ។ អាចដាច់ដោយឡែក និងរួមបញ្ចូលគ្នាដែលមិនឈានដល់ការធ្លាក់ចុះនៃចំណូលការប្រាក់សុទ្ធច្រើនជាង ២៥% បើប្រៀបធៀបទៅថវិកាចរន្ត ១២ខែទៅមុខ។ វិធីសាស្រ្តសាកល្បង រួមមានអាជីវកម្មថ្មីតាមថវិកា និងការសន្និដ្ឋានលម្អិតអំពីមូលដ្ឋានគ្រឹះនៃចលនារួមនៃអត្រាទ្រព្យសកម្ម និងបំណុល។ | ≤ ២៥% នៃការព្យាករណ៍ចំណូលការប្រាក់សុទ្ធសម្រាប់រយៈពេល ១២ ខែ |
| មូលធនសេដ្ឋកិច្ចដែលមានហានិភ័យគម្លាតរយៈពេល | ការប្រើគម្លាតនៃតម្លៃ ដែលអាចប្រែប្រួលតាមរយៈការថ្លឹងរយៈពេល (duration-weighted re-pricing gap) ក្នុងមួយរូបិយប័ណ្ណ មូលធនសេដ្ឋកិច្ចដែលមានហានិភ័យ ពីលក្ខខណ្ឌអត្រាដែលងាយនឹងប៉ះពាល់ដូចខាងក្រោម អាចដាច់ដោយឡែក ឬ រួមបញ្ចូលគ្នាដែលមិនបង្កឱ្យមានការខាតបង់ច្រើនជាង ២០% នៃមូលធនសរុប៖ ចំណុចមូលដ្ឋាន +២០០/-១០០ ក្នុងអត្រា swap ជាដុល្លារអាមេរិកក្នុងរយៈពេល ៤ ឆ្នាំ។ ចំណុចមូលដ្ឋាន +២០០/-២០០ ក្នុងធនាគារឈានមុខចំនួន ១០ នៅអត្រាប្រាក់បញ្ញើក្នុងរយៈពេល ១ ឆ្នាំ និង ចំណុចមូលដ្ឋាន +២០០/-២០០ អត្រា BIBOR អត្រាប្រាក់បាតថៃ ក្នុងរយៈពេល ៣ ខែ។ | ≤ ២០% នៃមូលនិធិផ្ទាល់សុទ្ធ |

*<u>ចំណាត់ការគ្រប់គ្រងហានិភ័យអត្រាការប្រាក់</u>*

ក្នុងករណីដែលការរៀបចំតារាងតុល្យការចរន្ត ឬ ព្យាករណ៍ អាចនាំឱ្យមានការបំពានលើហានិភ័យ អត្រាការប្រាក់មួយ ឬច្រើនដែលបានកំណត់ខាងលើនេះ គឺជាការទំនួលខុសត្រូវរបស់គណៈកម្មាធិការទ្រព្យសកម្ម និងបំណុលដើម្បីបង្កើតយុទ្ធសាស្រ្តក្នុងការកែតម្រូវតារាងតុល្យការរបស់ប្រាសាក់ ដើម្បីកាត់បន្ថយហានិភ័យអត្រាការប្រាក់ និងរក្សាកម្រិតនៃការគោរពតាមដែនកំណត់។

ឧបករណ៍គ្រប់គ្រងហានិភ័យអត្រាការប្រាក់ ដែលអាចទទួលយកបានដែលប្រាសាក់ ដាក់ឱ្យប្រើដើម្បីគ្រប់គ្រងហានិភ័យអត្រាការប្រាក់គឺ៖

- ការបង្កើតអត្រាប្រែប្រួល ឬ អត្រាថេរបន្ថែមលើទ្រព្យសកម្ម ឬ បំណុល ដែលមានរូបិយប័ណ្ណជាក់លាក់ដើម្បីទូទាត់អតុល្យភាពដែលមានស្រាប់
- ការលក់ទ្រព្យសកម្ម នូវអត្រាថេរ ឬ អត្រាប្រែប្រួលជាក់លាក់ ឬ ការទិញត្រលប់ (ការទូទាត់មុន) បំណុលនូវអត្រាថេរ ឬបំណុលអត្រាប្រែប្រួលសម្រាប់តម្លៃភ្លាមៗ
- ការប្រើប្រាស់ប្រតិបត្តិការអនាគតនូវអត្រាការប្រាក់រំលងបញ្ជរ ឬ មូលបត្រអត្រាថេរដែលមានរយៈពេលវែងដើម្បីទូទាត់កិច្ចសន្យាអត្រាការប្រាក់ថេរដែលមានស្រាប់លើទ្រព្យសកម្ម ឬ បំណុល
- ការបំលែងបំណុលអត្រាការប្រាក់ប្រែប្រួល ទៅជាបំណុលអត្រាការប្រាក់ថេរ ឬ ផ្ទុយមកវិញ ការប្រើកិច្ចព្រមព្រៀង swap។

គួរកត់សម្គាល់ថា ប្រតិបត្តិការត្រួតគ្នានៃឧបករណ៍និស្សន្ទ ដូចជាកិច្ចព្រមព្រៀងអត្រាការប្រាក់នៅពេលអនាគត និងកិច្ចព្រមព្រៀង swap តម្រូវឱ្យមានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល មានតម្លៃប្រហាក់ប្រហែលនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលតម្រូវសម្រាប់ប្រតិបត្តិការកម្ចីពាណិជ្ជកម្ម។ ក្រុមប្រឹក្សាភិបាលនឹងផ្តល់ការអនុញ្ញាតចំពោះតែប្រតិបត្តិការនាពេលអនាគតឬប្រតិបត្តិការប្តូរប្រាក់ក្នុងឧបករណ៍អត្រាការប្រាក់ សម្រាប់គោលបំណងនៃការកាត់បន្ថយនិភ័យ ឬ ការការពារ ហានិភ័យតែប៉ុណ្ណោះ។ ការជួញដូរឧបករណ៍បែបនេះ ឬ បង្កើតទីផ្សារសម្រាប់ឧបករណ៍ទាំងនេះ ស្ថិតក្រោមមូលហេតុប្រាក់ចំណេញឯករាជ្យដែលមិនពាក់ព័ន្ធនឹងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យអត្រាការប្រាក់ ហើយដែលជាពិសេសមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់នៅប្រាសាក់ឡើយ។

## ខ. ផលប៉ះពាល់នៃអតិផរណា

- អតិផរណាជាផ្នែកមួយដ៏សំខាន់សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ពីព្រោះវាបានផ្សាភ្ជាប់ទំនាក់ទំនងទៅនឹងអាជីវកម្មហិរញ្ញវត្ថុរបស់ប្រាសាក់ដូចជាការផ្តល់ឥណទាន ៨២,៣៦% នៃទ្រព្យសកម្មសរុបដែលក្នុងនោះ ១២,១៥% ឥណទានជាប្រាក់រៀល ០,៧៨% ជាប្រាក់ថៃបាត និង ៨៧,០៦% ជាប្រាក់ដុល្លារអាមេរិកផងដែរ។
- សេដ្ឋកិច្ចប្រទេសកម្ពុជាចាប់មានសន្ទុះខ្លាំងចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩ ជាមួយនឹងកំណើនផលិតផលក្នុងស្រុកសរុប ៧,០% ៧,០% ៧,៥% និង ៧,០% ក្នុងមួយឆ្នាំ។
- តាមកំណត់ត្រា ៥ ឆ្នាំចុងក្រោយបង្ហាញថាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) ជាមធ្យមនៃបម្រែបម្រួលជាភាគរយធៀបនឹងខែដូចគ្នានៃឆ្នាំមុនគឺអត្រា ២,៥% ក្នុងមួយឆ្នាំ។
- មួយភាគធំនៃសេដ្ឋកិច្ចកម្ពុជាគឺប្រើប្រាស់ជាប្រាក់ដុល្លារអាមេរិក ហើយអត្រាប្តូរប្រាក់ក៏មានការបម្រែបម្រួលតិចតួចក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។
- អត្រាភាពអត់ការងារធ្វើស្ថិតក្នុងកម្រិត ១,០២% ក្នុងឆ្នាំ២០១៩
- ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ផលិតផលក្នុងស្រុកសរុបដុលនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះក្នុង អត្រា -១,៦% (តាមរយៈរបាយការណ៍របស់មូលនិធិ រូបិយវត្ថុអន្តរជាតិក្នុងខែមេសា ឆ្នាំ២០២០)។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

- រាជរដ្ឋាភិបាលបានធ្វើការត្រៀមសាច់ប្រាក់ចំនួន ៨០០លានដុល្លារអាមេរិក ក្នុងការប្រើប្រាស់ករណីមានបញ្ហាបន្ទាន់ដែលប៉ះពាល់ពីការរីករាលដាល ជំងឺកូវីដ-១៩។

- កាត់បន្ថយពន្ធទៅលើវិស័យទេសចរណ៍ កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងកាត់បន្ថយចំណាយ លើថ្លៃប្រតិបត្តិការ។ កាត់បន្ថយថ្ងៃឈប់សម្រាករយៈពេល ៦ ថ្ងៃក្នុងមួយឆ្នាំដើម្បីបង្កើនផលិតភាពផលិតកម្ម។
- រាជរដ្ឋាភិបាលបានត្រៀមសាច់ប្រាក់បម្រុងចំនួន ៣ ប៊ីលានដុល្លារអាមេរិក សម្រាប់ការពារ ផលប៉ះពាល់ដែលអាចកើតឡើងពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងការផ្អាកការអនុគ្រោះពន្ធលើការនាំចេញទំនិញរបស់សហភាពអឺរ៉ុប (EBA) ។
- បានត្រៀមសាច់ប្រាក់បម្រុងពី ៦០០ ដល់ ៨០០លានដុល្លារអាមេរិក សម្រាប់ផ្តល់កម្ចីដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីជម្រុញសេដ្ឋកិច្ចជាតិ។
- ដាក់ចេញនូវសារាចរណែនាំដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឱ្យរៀបចំឥណទានឡើងវិញក្នុងអំឡុងពេលនៃការរីករាលដាលពីជំងឺកូវីដ-១៩។
- ចំពោះកម្ចីចាស់៖ កាត់បន្ថយអត្រាពន្ធកាត់ទុកមកត្រឹម ១០% ដោយអនុវត្តចាប់ពីខែមេសា រហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០២០។ ចំពោះកម្ចីថ្មី៖ កាត់បន្ថយអត្រាពន្ធកាត់ទុកមកនៅត្រឹម ៥% ដោយអនុវត្តចាប់ពីខែមេសា រហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០២០ បន្ទាប់មកត្រឹម ១០% ដោយអនុវត្តចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១ និងចាប់ពីឆ្នាំ២០២២ តទៅ ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចបង់ពន្ធកាត់ទុកតាមអត្រាធម្មតាវិញស្របតាមច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារជាធរមាន។
- ពន្យារពេលបើកប្រាក់អតីតភាពការងារដល់និយោជិតសម្រាប់ឆ្នាំ២០២០។
- កម្ពុជាបានកាត់បន្ថយរាល់ការចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ (ផែនការយុទ្ធសាស្ត្រ ២០២១-២០២៣)។
- រាជរដ្ឋាភិបាលបានរៀបចំ និងផ្តល់ថវិកាចំនួន ១២៥ លានដុល្លារអាមេរិក ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះជាង ៦០០.០០០ នាក់។
- រាជរដ្ឋាភិបាលបានកែសម្រួលវិធានការណ៍ក្នុងការធ្វើចត្តាឡីស័ក និងបានរៀបចំជាពិសេសសម្រាប់អ្នកវិនិយោគិនដែលមានសក្តានុពល អ្នកជំនាញបច្ចេកទេស និងអ្នកទីប្រឹក្សាយោបល់ ដែលមកដល់ព្រះរាជាណាចក្រកម្ពុជា។

**វិធានការរបស់ធនាគារជាតិនៃកម្ពុជា**

- ធនាគារជាតិនៃកម្ពុជាបានស្នើសុំឱ្យស្ថាប័នធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកាត់បន្ថយថ្លៃសេវាលើការផ្តល់ប្រាក់កម្ចី និងលើកលែងការដាកពិន័យដល់អ្នកខ្ចីក្នុងអំឡុងឆ្នាំដែលកំពុងតែប្រយុទ្ធប្រឆាំង និងការរាតត្បាតនៃជំងឺកូវីដ-១៩ ។
- លើកទឹកចិត្តឱ្យបន្តផ្តល់ប្រាក់កម្ចីទៅលើវិស័យអាទិភាព រួមមាន វិស័យទេសចរណ៍ កាត់ដេរ សំណង់ និងវិស័យផ្សេងៗទៀត។
- ពន្យារពេលនូវការអនុវត្តន៍តាមប្រកាសស្តីពីទ្រនាប់ដើមទុនខនស៊ើវេសិនរហូតដល់ឆ្នាំក្រោយ។
- បន្ថយអត្រាការប្រាក់ទៅលើប្រតិបត្តិការផ្តល់សន្ទនីយភាពមានការធានារហូតដល់អត្រា ០,៥% និងបញ្ចុះអត្រាការប្រាក់ទៅលើមូលបត្រដែលអាចជួញដូរបាន។
- បន្ថយអត្រាការប្រាក់ទៅលើសមតុល្យប្រាក់បញ្ញើសរុបពី ៨% សម្រាប់ប្រាក់រៀល និង ១២,៥% សម្រាប់ប្រាក់ដុល្លារអាមេរិក ទៅ ៧% រហូតដល់ ៦ខែបន្ទាប់ ដោយចាប់ផ្តើមពីខែមេសាតទៅ។
- បន្ថយអនុបាតក្របខ័ណ្ឌសន្ទនីយភាពដល់កម្រិតសមស្របណាមួយប្រសិនបើមានភាពចាំបាច់។
- ចេញគោលការណ៍ និងសេចក្តីណែនាំឱ្យរៀបចំឥណទានឡើងវិញក្នុងពេលប៉ះពាល់ដោយជំងឺកូវីដ-១៩ ជាពិសេសទៅលើវិស័យអាទិភាព។
- លើកទឹកចិត្តដល់គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ និងអតិថិជនឱ្យប្រើប្រាស់សេវាហិរញ្ញវត្ថុតាមប្រព័ន្ធឌីជីថល ប្រសើរជាងការប្រើប្រាស់មូលប្បទានបត្រ និងសាច់ប្រាក់ក្នុងការទូទាត់ចំណាយ។
- ដើម្បីរក្សាស្ថេរភាពអត្រាប្តូរប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានដាក់ដេញថ្លៃការ(លក់)ប្រាក់ដុល្លារ ចំនួនបួនលើកនៅក្នុងខែតុលា និង ខែវិច្ឆិកា ២០២០ ក្នុងចំនួនសរុប ១០០ លានដុល្លារអាមេរិក ។

# ផ្នែកទី ៩ - ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

សញ្ញាប័ណ្ណសាជីវកម្មប្រាសាក់ ជាសញ្ញាប័ណ្ណទទួលបានការធានាពីស្ថាប័ន Credit Guarantee and Investment Facility (CGIF)។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈមិនមានលក្ខខណ្ឌតម្រូវឱ្យធ្វើចំណាត់ថ្នាក់ លទ្ធភាពសងលើសញ្ញាប័ណ្ណសាជីវកម្មនោះទេ ប៉ុន្តែបុគ្គលធានាតម្រូវឱ្យមានចំណាត់ថ្នាក់លទ្ធភាពសង។

ភាពខ្លាំងរបស់ ស្ថាប័ន CGIF ចំពោះលទ្ធភាពនៃការទូទាត់សង៖

- "AA/A-1+" កម្រិតសកល (រយៈពេលវែង និងរយៈពេលខ្លី) ទស្សនវិស័យស្ថិរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង S&P នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨
- "gAAA/seaAAA/AAA" កម្រិតសកល/អាស៊ាន/ជាតិ ទស្សនវិស័យស្ថិរភាពកំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង RAM Rating នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩
- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថិរភាពកំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង MARC នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩
- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថិរភាពកំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង TRIS Rating នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨
- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថិរភាពកំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Fitch Rating នៃប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

សញ្ញាប័ណ្ណត្រូវបានធានាដោយស្ថាប័នCGIF ។ អនុលោមតាមការធានារបស់ស្ថាប័នCGIF ស្ថាប័ននេះនឹងធ្វើការធានាដោយមិនអាចប្រកែកបាន និងមិនមានលក្ខខណ្ឌចំពោះភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល លើការទូទាត់សងទាំងស្រុង និងទៀងទាត់ពេលវេលានៃទំហំដែលធានា។ សម្រាប់គោលបំណងនៃការធានាដោយស្ថាប័ន CGIF «ទំហំដែលធានា» សំដៅដល់៖

- ទំហំប្រាក់ដើម និងការប្រាក់ណាមួយដែលហួសកាលកំណត់សង និងមិនបានទូទាត់សង (មិនថាទាំងស្រុង ឬមួយផ្នែក) ដោយក្រុមហ៊ុនបោះផ្សាយស្ថិតក្រោមលក្ខខណ្ឌនៃមូលបត្របំណុល និងកិច្ចព្រមព្រៀងអ្នកកាន់កាប់មូលបត្របំណុល
- ការប្រាក់បង្គរបន្ថែម និងចំណាយរបស់ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលណាមួយ (ករណីនីមួយៗ ត្រូវបានកំណត់នៅក្នុងការធានារបស់ស្ថាប័ន CGIF)
- ទំហំដែលធានាជាលក្ខខណ្ឌនៃការធានាក្នុងទម្រង់ដែលបានភ្ជាប់ក្នុងឧបសម្ព័ន្ធ គ នៃលក្ខខណ្ឌនៃមូលបត្របំណុល (ការធានារបស់ស្ថាប័ន CGIF)។

## ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព



ជ. លោក Kwi Sang JUN
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព



ជ. លោក Ji Kyu JANG
សមាជិកក្រុមប្រឹក្សាអភិបាល

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព



ជ. លោក Ishara C Nanayakkara
សមាជិកក្រុមប្រឹក្សាអភិបាល

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
បានអាន នឹងឯកភាព



ជ. លោក Minki Brian HONG
សមាជិកក្រុមប្រឹក្សាអភិបាល

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
បានអាន នឹងឯកភាព



លោក ស៊ីម សេនាជាតិ
សមាជិកក្រុមប្រឹក្សាអភិបាល

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក**

អគារលេខ ២១២ ផ្លូវ ២៧១ សង្កាត់ទួលទំពូង ២ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ ០២៣ ២២០ ១០២ | សេវាអតិថិជន៖ ០២៣ / ០៨៦ ៩៩៩ ៩១១ | ទូរសារ៖ ០២៣ ២១៦ ៣៦២ | ប្រអប់សំបុត្រ៖ ២៤១២
អ៊ីម៉ែល៖ info@prasac.com.kh | វេបសាយត៍៖ www.prasac.com.kh | ចុះបញ្ជីពាណិជ្ជកម្មលេខ៖ ០០០០១១៥៧
គ្រឹះស្ថានឯកជន